ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២៣ ២០១៩

តម្លៃ ១.៥០០៛

30th ANNIVERSARY CDRI 1990 - 2020

# អភិបាលកិច្ចសន្តិសុខអ៊ីនធើណិតនៅកម្ពុជា៖ ស្ថានភាពបច្ចុប្បន្ន និងអាទិភាពទៅអនាគត

## សេចក្ដីផ្ដើម

អត្ថបទនេះពិភាក្សាពីបញ្ហាសុវត្ថិភាពអ៊ិនធើណិត បទល្មើសតាមអ៊ីនធើណិត និងអភិបាលកិច្ចសន្តិសុខអ៊ីនធើណិត ដោយពិនិត្យឡើងវិញពីគោលនយោបាយ និងប្រព័ន្ធអភិបាលកិច្ចនាពេលបច្ចុប្បន្ន នៅកម្ពុជា និងនៅប្រទេសអាស៊ានដទៃទៀត ព្រមទាំងធ្វើការវាយតម្លៃពីយុទ្ធសាស្ត្រ និងផែនការរបស់ក្រសួងនានា មជ្ឈមណ្ឌលស្រាវជ្រាវ និងក្រុមហ៊ុនអន្តរជាតិធំៗ។

បុគ្គល ស្ថាប័នរដ្ឋ និងអង្គការនានា កាន់តែពឹងផ្អែកខ្លាំងឡើង ទៅលើប្រព័ន្ធអេកូបច្ចេកវិទ្យាស្មុគស្មាញ ដើម្បីប្រាស្រ័យទាក់ទង និងធ្វើអន្តរកម្មជាមួយអ្នកមានជំនាញដូចគ្នា ដៃគូអាជីវកម្ម និងអតិថិជន, ចែករំលែក និងទទួលបានព័ត៌មាន, ផ្ដល់ទិន្នន័យ សម្រាប់កែលំអការសម្រេចចិត្ត និងលទ្ធផល, និងបង្កើនលទ្ធភាពឈោងដល់ និងផលចំណេញ។ ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល កាន់តែចាំបាច់ឡើងទៀតក្នុងពេលមានជំងឺឆ្លងរាលដាលដូច កូវីដ១៩ នាពេលបច្ចុប្បន្ន។ ក្នុងពេលជាមួយគ្នា ការវាយប្រហារតាមអ៊ិនធើណិត បានកើតមានឡើងកាន់តែញឹកញាប់ និងធ្ងន់ធ្ងរ។ ទាំងបុគ្គលឯកជន អ្នកនយោបាយ សមាជិកក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងអង្គភាព កាន់តែបានដឹងច្បាស់ថា នវានុវត្តន៍ផ្អែកលើបច្ចេកវិទ្យា និងគំនិតផ្ដួចផ្ដើមផ្សេងៗ វាបើកច្រកនាំឲ្យមានហានិភ័យតាមអ៊ិនធើណិត និងបញ្ហាប្រឈមកាន់តែធំផ្អែកអភិបាលកិច្ច។

ដោយសារវាជាប្រធានបទថ្មីសម្រាប់កម្ពុជា ការសិក្សានេះមានគោលដៅលើកកម្ពស់ចំណាប់អារម្មណ៍ និងបំផុសកិច្ចសន្ទនាដ៏មានប្រយោជន៍ តាមការសម្រួលឲ្យលទ្ធផលស្រាវជ្រាវបានជ្រាបទៅដល់អ្នកកសាងនយោបាយ មន្ត្រីរដ្ឋាភិបាល និងអ្នកដឹកនាំសហគ្រាស សម្រាប់ការកសាងយុទ្ធសាស្ត្រ និងការបង្កើត និងកែលំអក្របខ័ណ្ឌសន្តិសុខអ៊ិនធើណិតរបស់ខ្លួន (ពោលគឺ




*ប្រទេសកម្ពុជាកំពុងខិតខំពង្រឹងអភិបាលកិច្ចសន្តិសុខតាមអ៊ិនធើណិត ដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមានពីទំនាក់ទំនងសកលកាន់តែខ្លាំងឡើង ខែតុលា ឆ្នាំ២០១៩*

អភិបាលកិច្ច បច្ចេកវិទ្យា សមត្ថភាព និងសហប្រតិបត្តិការ)។ អ្នកនិពន្ធសង្ឃឹមថា អ្នកស្រាវជ្រាវ និងអ្នកអនុវត្តជាក់ស្ដែង អាចជួយពង្រីកលទ្ធផលរកឃើញទាំងនេះ និងតាមទាន់បច្ចេកវិទ្យាថ្មីៗ និងការផ្លាស់ប្តូរបច្ចេកវិទ្យាយ៉ាងលឿននៅកម្ពុជា។

## សន្តិសុខអ៊ីនធើណិតនៅកម្ពុជា និងនៅក្នុងសកលលោក

កម្ពុជាមានសេដ្ឋកិច្ចកើនឡើងយ៉ាងលឿន ដល់ ៧,៥% នៅឆ្នាំ២០១៨ (World bank 2019) ពោលគឺកើនឡើងលឿន

---

សូមយោងអត្ថបទនេះថា៖ A CDRI Publication. 2019. “Cybergovernance in Cambodia: Current State and Future Priorities.” *Cambodia Development Review* vol. 23, 2019: 1–6។

## មាតិកា

អភិបាលកិច្ចសន្តិសុខអ៊ិនធើណិតនៅកម្ពុជា៖ ស្ថានភាពបច្ចុប្បន្ន និងអាទិភាពទៅអនាគត ........................................ ១
ការពិនិត្យឡើងវិញពី ការអភិវឌ្ឍ និងអនុវត្តការអប់រំនិងបណ្តុះបណ្តាលផ្អែកលើសមត្ថភាព ............................... ៧
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ......................១២
– ស្ថានភាពក្នុងប្រទេស........................ ១៥
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ..........................................២៤

រូបភាព១៖ ស្ថិតិផ្នែកឌីជីថលនៅកម្ពុជា




ប្រភព៖ Ou 2018 (តាមការអនុញ្ញាតពីអ្នកនិពន្ធ)

បំផុតក្នុងតំបន់អាស៊ាន និងស្ថិតក្នុងចំណោមប្រទេសមានសេដ្ឋកិច្ចកើនឡើងលឿនបំផុតក្នុងពិភពលោក។ ទន្ទឹមនឹង កំណើនសេដ្ឋកិច្ចគួរកោតសរសើរនេះ ស្ថាប័នរដ្ឋ ក្រុមហ៊ុន និងអង្គការនានានៅកម្ពុជា កំពុងពង្រីកការប្រើប្រាស់បច្ចេកវិទ្យាយ៉ាងលឿន (រូបភាព១)។ កំណើនការប្រើប្រព័ន្ធឌីជីថលនេះ ជំរុញឡើងជាសំខាន់ ដោយសារប្រជាជនកម្ពុជាមួយភាគធំមានវ័យក្មេង ពោលគឺ មានអាយុមធ្យម (median age) ត្រឹម ២៥,៦ឆ្នាំ។

ចាប់ពីឆ្នាំ២០១៧ ដល់ ២០១៩ ចំនួនអ្នកប្រើប្រាស់បណ្ដាញសង្គមកើន ៧១% ពី ៤,៩លាននាក់ ដល់ ៨,៤លាននាក់ គឺជិតដល់ពាក់កណ្ដាលនៃប្រជាជនសរុប (Kepios Analysis 2019)។ ស្ថិតិទាំងនេះ បង្ហាញពី ស្ថានភាពល្អក្នុងប្រទេសទាំងមូលក៏ពិតមែន ប៉ុន្តែការជឿនលឿនយ៉ាងឆាប់រហ័សខាងផ្នែកបច្ចេកវិទ្យាបែបនេះមែន អាចធ្វើឲ្យកម្ពុជាងាយរងគ្រោះដោយសារការវាយប្រហារតាមអ៊ិនធើណិត បើសិនពុំមានការកែលំអក្របខ័ណ្ឌសន្តិសុខអ៊ិនធើណិតនោះទេ។ ជនល្មើសតាមអ៊ិនធើណិត កំពុងប្រើប្រាស់ឧបករណ៍កាន់តែទំនើប និងងាយពង្រីកថែម ដើម្បីជ្រៀតចូលយកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើអ៊ិនធើណិត ហើយពួកវាសម្រេចបានលទ្ធផលមួយចំនួន។

ជនល្មើសតាមអ៊ិនធើណិត (បុគ្គលឯកជន អ្នកសកម្មវាយលុក និង/ឬ ជនល្មើសមានរដ្ឋជួយឧបត្ថម្ភ) តែងផ្ដោតលើតំណ (link) ខ្សោយបំផុតក្នុងអ៊ិនធើណិត ពោលគឺ តាមធម្មតាក្រុមហ៊ុនធំៗតែងរងគ្រោះច្រើនពីការវាយប្រហារតាមអ៊ិនធើណិត ដែលត្រូវបានអនុវត្តឡើងឆ្លងតាម ដៃគូជាភាគីទី៣ អ្នកផ្គត់ផ្គង់ និងអ្នកលក់នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុន។

តម្រូវការឲ្យមាន ក្របខ័ណ្ឌអភិបាលកិច្ចសន្តិសុខអ៊ិនធើណិត គឺមាន គេយល់ស្របកាន់តែច្រើនឡើងហើយថាជាទិដ្ឋភាពសំខាន់មួយ នៃការកាត់បន្ថយហានិភ័យតាមប្រព័ន្ធអ៊ិនធើណិត។ សន្តិសុខអ៊ិនធើណិត រួមទាំង អភិបាលកិច្ចសន្តិសុខអ៊ិនធើណិតផងជាអាទិភាពទី៦ ក្នុងចំណោមអាទិភាពសកលទាំង ១០ សម្រាប់ឆ្នាំ២០១៩ ពោលគឺ ខ្ពស់ជាងអាទិភាពនៃការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មឆ្លងប្រទេស និង ការលើកកម្ពស់សុខភាពសកលទៅទៀត និងស្ថិតក្នុងចំណោម បញ្ហាប្រឈមផ្នែកគោលនយោបាយបន្ទាន់ៗជាងគេក្នុងពិភពលោក។

## ក្របខ័ណ្ឌអភិបាលកិច្ចសន្តិសុខអ៊ិនធើណិតនៅកម្ពុជា

យ៉ាងហោចណាស់ក្នុងទ្រឹស្ដីដែរ ក្របខ័ណ្ឌសន្តិសុខអ៊ិនធើណិត រួមមាន អភិបាលកិច្ច (ច្បាប់ សមត្ថភាពបច្ចេកទេស ការដឹកនាំ) បច្ចេកវិទ្យា (សមត្ថភាពបច្ចេកទេស និងស្ថាប័ន) និង ប្រតិបត្តិការ (ការកសាងសមត្ថភាព សហប្រតិបត្តិការ និងភាពជាដៃគូ) ព្រមទាំង តួអង្គសំខាន់ៗ ដូចជា មន្ទីរក្រសួងរដ្ឋ តុលាការ ស្ថាប័នពង្រឹងអនុវត្តច្បាប់ សហគមន៍ស៊ើបការណ៍ម្ចាស់ និងប្រតិបត្តិករហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ អ្នកលក់ដូរ អ្នកសិក្សាអប់រំ ពលរដ្ឋ និង អ្នកពាក់ព័ន្ធបរទេស។

នៅពេលអ្នកនិពន្ធកំពុងតាក់តែងអត្ថបទនេះ គឺមានសេចក្ដីព្រាងច្បាប់ថ្មីមួយស្ដីពី បទល្មើសតាមអ៊ិនធើណិត ដែលត្រូវបានលើកយកមកពិភាក្សានៅក្រសួងមហាផ្ទៃ ហើយគេរំពឹងថានឹងមានការកែប្រែជាច្រើនទៀត នៅក្នុងសេចក្ដីព្រាងច្បាប់ដំបូងឆ្នាំ២០១៤ នេះ ។ ដោយសារសេចក្ដីព្រាងច្បាប់ចុងក្រោយមិនទាន់មានការផ្សព្វផ្សាយជាសាធារណៈ ដូច្នេះការវិភាគនៅខាងក្រោមផ្អែកលើសេចក្ដីព្រាងច្បាប់ឆ្នាំ២០១៤ (ជាភាសាខ្មែរ និងអង់គ្លេស) ដែលមិនទាន់ផ្លូវការនៅឡើយ។

គោលដៅនៃ សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសតាមអ៊ិនធើណិតឆ្នាំ២០១៤ គឺដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសផ្សេងៗដែលអនុវត្តឡើងតាមប្រព័ន្ធកុំព្យូទ័រ (ឧបករណ៍មួយ ឬ ឧបករណ៍តភ្ជាប់គ្នាមួយខ្សែ) និងដើម្បីការពារ និងធានាសុវត្ថិភាពសិទ្ធិស្របច្បាប់ និងផលប្រយោជន៍របស់នីតិបុគ្គល និងរូបវន្តបុគ្គល និងរបស់ប្រទេសកម្ពុជា។ ក្នុងនេះរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិប្រឆាំងនឹងបទល្មើសតាមអ៊ិនធើណិត (NACC) ដែលមាននាយករដ្ឋមន្ត្រីជាប្រធាន ដើម្បីកសាងយុទ្ធសាស្ត្រផែនការសកម្មភាព និងវិធានការជាប់ទាក់ទិនផ្សេងៗខាង

រូបភាព២៖ ភាពងាយរងគ្រោះពីការវាយប្រហារតាមអ៊ិនធើណិត




ប្រភព៖ Ou 2018 (តាមការអនុញ្ញាតពីអ្នកនិពន្ធ)

សន្តិសុខអ៊ិនធើណិត និងប្រព័ន្ធព័ត៌មាន សម្រាប់រដ្ឋាភិបាល។ ច្បាប់នេះក៏បានផ្តល់អំណាច "គោលនយោបាយតុលាការ" ដល់អគ្គនាយក និងអគ្គនាយករង នៃលេខាធិការដ្ឋាន NACC ដើម្បីធ្វើការឃាត់ខ្លួន និងស៊ើបអង្កេតលើសកម្មភាពរបស់ជនជាប់សង្ស័យ (មាត្រា១៥)។

សរុបមក ខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ សំដៅដោះស្រាយការព្រួយបារម្ភអំពី បទល្មើសធម្មតាតាមអ៊ិនធើណិត ដូចជា ការលួចចូលខុសច្បាប់ ចារកម្មទិន្នន័យ ការលួចកម្មសិទ្ធិបញ្ញា ជាដើម ដោយមានការកំណត់ទោសទណ្ឌ សម្រាប់បទល្មើសនីមួយៗ។ ប៉ុន្តែនៅមានបញ្ហាចោទជាច្រើនទៀត ជាពិសេស ទាក់ទងនឹងមាត្រា២៨ ដែលអាចរឹតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ ឧទាហរណ៍ កថាខ័ណ្ឌ៤ នៃមាត្រា២៨ ចែងថា ការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីរដ្ឋាភិបាល ជាបទល្មើសអាចផ្តន្ទាទោសតាមច្បាប់។ ប៉ុន្តែក្នុងនោះ រដ្ឋាភិបាល គឺជាអ្នកកំណត់ថា ការផ្សព្វផ្សាយណាមួយជា "ព័ត៌មានមិនពិត"។

ដោយសារបទល្មើសតាមអ៊ិនធើណិត មានលក្ខណៈបន្ទាន់ស្មុគស្មាញ និងប៉ះពាល់ដល់គ្រប់ទិដ្ឋភាពសង្គម ដូច្នេះបទបញ្ញត្តិស្តីពីបទល្មើសតាមអ៊ិនធើណិត ត្រូវមានកិច្ចប្រឹងប្រែងដោយរួមសហការគ្នារវាង វិស័យសាធារណៈ វិស័យឯកជន និង វិស័យសិក្សាអប់រំ។

## លទ្ធផលរកឃើញសំខាន់ៗ និងការផ្តល់មតិ

ចំណុចខ្វះខាតសំខាន់ៗ បួន បានលេចចេញពីការវិភាគលើកិច្ចប្រឹងប្រែងផ្នែកអភិបាលកិច្ចសន្តិសុខអ៊ិនធើណិត និងការជំរុញកិច្ចប្រឹងប្រែងនេះ គឺមាន៖

- តម្លាភាពរបស់រដ្ឋាភិបាល
- ធនធានមនុស្ស និងបច្ចេកទេស
- កិច្ចសហការក្នុងតំបន់
- គោលដៅជាក់ស្តែងអាចវាស់វែងបាន

***ការផ្តល់មតិទី១៖*** កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការកសាងក្របខ័ណ្ឌសន្តិសុខអ៊ិនធើណិតរបស់ខ្លួន ដោយប្រឹងដោះស្រាយចំណុចខ្វះខាតសំខាន់ៗទាំងបួនខាងលើ ជាពិសេសក្នុងបញ្ហា តម្លាភាព និង កិច្ចការពារសិទ្ធិមនុស្ស និងផលប្រយោជន៍ជាតិ, ការកសាងកម្លាំងពលកម្មមានជំនាញខ្ពស់សម្រាប់ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនាពេលអនាគត, និងការបង្កើតភាពជាដៃគូជាយុទ្ធសាស្ត្រជាមួយប្រទេសដទៃទៀត និងក្រុមហ៊ុនអន្តរជាតិនានា។ ក្នុងស្ថានភាពបច្ចុប្បន្ន ជាប្រទេសកំពុងអភិវឌ្ឍ កម្ពុជានៅមានឧបសគ្គធំៗត្រូវដោះស្រាយមួយរយៈពេលទៀត ប៉ុន្តែការប្រើប្រាស់របៀបរបបអន្តរជាតិល្អៗ ដូចជា ស្តង់ដា និងក្របខ័ណ្ឌផ្សេងៗជាដើម អាចជួយកម្ពុជាក្នុងការដាក់អនុវត្តប្រព័ន្ធមានប្រសិទ្ធភាព និងដំណើរការបានល្អ ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធ នៃបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ICT) របស់ខ្លួន និងអ្នកប្រើប្រាស់ អំពីការវាយប្រហារតាមអ៊ិនធើណិត។

ក្នុងចក្ខុវិស័យ ដើម្បីក្លាយជាប្រទេសអភិវឌ្ឍន៍ពេញលេញនៅឆ្នាំ២០៥០ (Seangly 2013) កម្ពុជាបានកំណត់គោលដៅប្រកបដោយមហិច្ឆតាជាច្រើន មានជាអាទិ៍ ការធ្វើវិនិយោគយ៉ាងច្រើនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការអភិវឌ្ឍទីក្រុងឆ្លាត និងការអនុវត្តតាមគោលការណ៍នៃឧស្សាហកម្ម ៤.០ នៅក្នុងកម្មន្តសាលកម្ម។ ការវាយប្រហារទ្រង់ទ្រាយធំ តាមអ៊ិនធើណិត ទៅលើបច្ចេកវិទ្យាទាំងនេះមុនពេលវាអនុវត្តបានពេញលេញ និងមានសន្តិសុខល្អ អាចបង្កឧបសគ្គធ្ងន់ធ្ងរដល់ប្រសិទ្ធភាពនិងការរីកចម្រើនរបស់វា ហើយតាមនេះអាចបង្កផលលំបាកដោយផ្ទាល់ដល់កំណើនសេដ្ឋកិច្ចកម្ពុជា។

***ការផ្តល់មតិទី២៖*** កិច្ចការពារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជា សុខាភាពសាធារណៈ ការដឹកជញ្ជូន ប្រព័ន្ធទូរគមនាគមន៍ និងការផ្គត់ផ្គង់ទឹក និងអគ្គិសនី គឺជាទំនួលខុសត្រូវចម្បងរបស់

រដ្ឋាភិបាល ហើយគួរដោះស្រាយតាមការរួមដៃគ្នា ជាធ្លុងមួយ រវាងវិស័យសាធារណៈ វិស័យឯកជន នឹងវិស័យសិក្សាអប់រំ។

***ការផ្តល់មតិទី៣៖*** ច្បាប់ និងបទបញ្ញត្តិស្តីពីសន្តិសុខអ៊ិនធើណិត ត្រូវតែអនុម័តចេញ។ ឧទាហរណ៍យ៉ាងល្អមួយនៃច្បាប់សន្តិសុខអ៊ិនធើណិតដែលត្រូវបានគ្រោងឡើងយ៉ាងហ្មត់ចត់ គឺច្បាប់សន្តិសុខអ៊ិនធើណិតឆ្នាំ២០១៨ របស់សិង្ហបុរី។ ច្បាប់នេះបានចែងយ៉ាងលំអិត និងច្បាស់ៗថា អង្គការជាប់ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅសិង្ហបុរីមួយណាត្រូវធ្វើអ្វីខ្លះ និងបានកំណត់ច្បាស់ថា រដ្ឋាភិបាលអាចធ្វើអ្វី និងមិនអាចធ្វើអ្វីក្នុងការការពារសន្តិសុខជាតិ (Republic of Singapore 2018)។ ជាជាងសេចក្តីចែងមិនសូវច្បាស់ពី បទល្មើស និងតុល្យភាពអំណាច ច្បាប់សន្តិសុខអ៊ិនធើណិតរបស់សិង្ហបុរី បានផ្តោតលើការធានា ឲ្យមានសហប្រតិបត្តិការ និងតម្លាភាពរវាងវិស័យសាធារណៈ នឹងវិស័យឯកជន។

សម្រាប់កម្ពុជា ច្បាប់ស្តីពីសន្តិសុខអ៊ិនធើណិត គួរផ្តោតលើការទប់ស្កាត់ និងការឆ្លើយតបនឹងការវាយប្រហារ តាមអ៊ិនធើណិតដោយប្រើបច្ចេកទេសខ្ពស់ ទៅលើហេដ្ឋារចនាសម្ព័ន្ធ រដ្ឋាភិបាល និងអាជីវកម្មនានា ព្រោះផលប៉ះពាល់របស់វា ទៅលើសេដ្ឋកិច្ចកម្ពុជាអាចធំធេងខ្លាំងជាងបទល្មើស និងការចាត់ទុក ជាជនល្មើសច្បាប់ ដោយសារតែការផ្សព្វផ្សាយព័ត៌មានដែលជាចំណុចផ្តោតនៃសេចក្តីព្រាងច្បាប់ ស្តីពី បទល្មើសតាមអ៊ិនធើណិតឆ្នាំ២០១៤ ទៅទៀត។

***ច្បាប់ស្តីពីសន្តិសុខអ៊ិនធើណិត គួរផ្តោតលើការទប់ស្កាត់ និងការឆ្លើយតបនឹងការវាយប្រហារតាមអ៊ិនធើណិតដោយប្រើបច្ចេកទេសខ្ពស់ ទៅលើ ហេដ្ឋារចនាសម្ព័ន្ធ រដ្ឋាភិបាល និង អាជីវកម្មនានា ព្រោះផលប៉ះពាល់របស់វាទៅលើ សេដ្ឋកិច្ចកម្ពុជា អាចធំធេងខ្លាំងជាង បទល្មើស និងការចាត់ទុកជាជនល្មើសច្បាប់***

ការត្រួតពិនិត្យជាប់រហូតលើការជឿនលឿនទៅមុន និងលទ្ធផលបានវាស់វែងជាក់លាក់ ពីសំណាក់អាជ្ញាធរអភិបាលកិច្ចសន្តិសុខអ៊ិនធើណិតថ្នាក់ជាតិមួយ (NACC) ដែលមានសមាសភាពមកពីខាង រដ្ឋាភិបាល អាជីវកម្មសំខាន់ៗ និងភាគីពាក់ព័ន្ធមិនមែនរដ្ឋាភិបាលផ្សេងៗ ហើយអាជ្ញាធរនេះមានទំនួលខុសត្រូវតែមួយគត់គឺ ធានាភាពធន់នៃប្រព័ន្ធឌីជីថលកម្ពុជា។

សព្វថ្ងៃមាន ស្តង់ដា និងក្របខ័ណ្ឌសន្តិសុខអ៊ិនធើណិតជាច្រើនដែលគេបានទទួលស្គាល់ ហើយដែលគេអាចយកមកប្រើដើម្បីកសាងកម្មវិធីអភិបាលកិច្ចសន្តិសុខអ៊ិនធើណិត។ ក្នុងនេះក្របខ័ណ្ឌសម្រាប់កែលំអសន្តិសុខអ៊ិនធើណិត នៃហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ (NIST 2018) (បង្កើតឡើងដោយ វិទ្យាស្ថានជាតិផ្នែកស្តង់ដា និងបច្ចេកវិទ្យា (NIST) នៅសហរដ្ឋអាមេរិក ដើម្បីឆ្លើយតបនឹងការរីកចម្រើនបច្ចេកវិទ្យាយ៉ាងលឿន និងកំណើនការគំរាមកំហែងលើសន្តិសុខអ៊ិនធើណិត) គឺកំពុងកើនប្រជាប្រិយភាពយ៉ាងលឿន ដោយសារ មានការប្រើវិធីសាស្ត្រផ្អែកលើហានិភ័យ និងការប្រើពាក្យពេចន៍ច្បាស់ៗអាចយល់បាន។ កម្ពុជាគួរស្រង់យកបទពិសោធន៍នេះ ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីពង្រឹងសន្តិសុខ និងភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ របស់ប្រទេសជាតិ និងដើម្បីថែរក្សានូវបរិស្ថានអ៊ិនធើណិតមួយ ដែលលើកទឹកចិត្ត ឲ្យមានប្រសិទ្ធភាពនវានុវត្តន៍ និងការរីកចម្រើនសេដ្ឋកិច្ច ហើយទន្ទឹមគ្នានោះ ក៏ពង្រឹងសុវត្ថិភាព សន្តិសុខ ការរក្សាការសម្ងាត់របស់អាជីវកម្ម ការការពារឯកជនភាពនិងសេរីភាពរបស់ពលរដ្ឋផងដែរ។

***ការផ្តល់មតិទី៤៖*** ការកសាងកម្មវិធីអភិបាលកិច្ច និងសន្តិសុខអ៊ិនធើណិត ឲ្យទៅជាក្របខ័ណ្ឌសន្តិសុខអ៊ិនធើណិត វាស្មុគស្មាញជាខ្លាំង ព្រោះជាប់ទាក់ទងដល់គ្រប់ឧស្សាហកម្ម និងរបៀបរបបរស់នៅ និងជាប់ពាក់ព័ន្ធដល់អាជ្ញាធរគ្រប់កម្រិត ហើយអាចមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដោយផ្ទាល់ដល់សេដ្ឋកិច្ច និងសង្គម។ តាមនេះរដ្ឋាភិបាលគួរពិចារណាលើសកម្មភាពដូចតទៅ ក្នុងការកសាងកម្មវិធី អភិបាលកិច្ចសន្តិសុខអ៊ិនធើណិតរបស់ខ្លួន៖ យុទ្ធសាស្ត្រជាតិ ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ កិច្ចសហការរវាងវិស័យសាធារណៈនឹងឯកជន បទបញ្ញត្តិគ្រប់គ្រងសន្តិសុខអ៊ិនធើណិត ការអនុម័តប្រើស្តង់ដាសន្តិសុខអ៊ិនធើណិតមួយចំនួន ការចែករំលែកព័ត៌មានក្នុងតំបន់ ការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ និង ការកសាងសមត្ថភាព។ សកម្មភាពនីមួយៗដូចខាងលើនេះ តំណាងឲ្យគម្រោងមួយ ដែលគួរមាន

***ការផ្តល់មតិទី៥៖*** ការកសាងកម្មវិធី សន្តិសុខអ៊ិនធើណិតដោយប្រើគំរូ ដូចជា ក្របខ័ណ្ឌសន្តិសុខ NIST ជាដើម អាចជួយផ្តល់នូវភាសារួមគ្នាមួយ សម្រាប់ការប្រាស្រ័យទាក់ទងគ្នាអំពីហានិភ័យតាមអ៊ិនធើណិតរវាង កម្រិតផ្សេងៗនៃរដ្ឋាភិបាល និងវិស័យផ្សេងៗនៃឧស្សាហកម្ម ដែលត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល សំខាន់ៗនៅកម្ពុជា។ ម៉្យាងទៀត គោលនយោបាយលើសន្តិសុខអ៊ិនធើណិតនាបច្ចុប្បន្ន ការបណ្តុះបណ្តាល និងដំណោះស្រាយផ្សេងៗ គួរមានកំណត់គោលដៅទៅអនាគត និងផ្តល់អាទិភាពដល់នវានុវត្តន៍ ព្រមទាំងតាមដាននិងផ្សព្វផ្សាយពីដំណើរការជឿនលឿនទៅដល់អ្នកពាក់ព័ន្ធនានា។ កិច្ចការនេះអាចសម្រេចបានតាមការបំបែកសន្តិសុខអ៊ិនធើណិត និងអភិបាលកិច្ច ទៅជាចំណុចសំខាន់ៗសម្រាប់ធ្វើការអភិវឌ្ឍ៖

១. ការកំណត់ទ្រព្យសម្បត្តិ ដើម្បីឲ្យមានបរិបទច្បាស់ សម្រាប់ការស្វែងយល់ពីហានិភ័យតាមអ៊ិនធើណិត
២. ការការពារទ្រព្យសម្បត្តិដោយដាក់អនុវត្តប្រព័ន្ធការពារ
៣. ការរកឲ្យឃើញភាពមិនប្រក្រតីផ្សេងៗក្នុងអ៊ិនធើណិត នៅពេលវាកើតមានឡើង
៤. ការឆ្លើយតបនឹងព្រឹត្តិការណ៍អ៊ិនធើណិតផ្សេងៗ នៅពេលរកវាឃើញ
៥. ការស្តារមកកាន់ស្ថានភាពដើមវិញ បន្ទាប់ពីកើតមានហេតុការណ៍ក្នុងអ៊ិនធើណិត

***ការផ្តល់មតិទី៦៖*** របៀបរបបអនុវត្តល្អៗនៅអន្តរជាតិ ក៏គួរយកមកកែសម្រួលប្រើដែរ ដើម្បីធ្វើការវាយតម្លៃជាលក្ខណៈប្រព័ន្ធ និងតាមដានកម្រិតភាពធន់ នៃសន្តិសុខអ៊ិនធើណិតនាបច្ចុប្បន្ន ហើយអាចរកឃើញចន្លោះខ្វះខាតនៅក្នុងវិធានការទប់ស្កាត់ និងសម្រាលគ្រោះថ្នាក់ផ្សេងៗ។ នៅពេលរកឃើញចន្លោះខ្វះខាតទាំងនេះហើយ គួរកំណត់អាទិភាពឲ្យវា ដោយផ្អែកលើទំហំគ្រោះថ្នាក់ទៅដល់ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថលកម្ពុជា ក្នុងនោះមានទាំង ការវិភាគពីការគំរាមកំហែង និងលទ្ធភាពមានការវាយប្រហារតាមអ៊ិនធើណិតផង។ នៅពេលកំណត់កម្រិតនៃហានិភ័យនិងការគំរាមកំហែងបានហើយ គួរមានលើកសំណើពីដំណោះស្រាយទៅដល់ថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីសុំការឧបត្ថម្ភគាំទ្រ និងមូលនិធិ។

***ការផ្តល់មតិទី៧៖*** សន្តិសុខអ៊ិនធើណិតជាប្រធានបទមួយដែលគ្រប់គ្នាត្រូវយល់ដឹង ហើយសហគមន៍ព័ត៌មានវិទ្យា (IT) គួរជួយធ្វើឲ្យព័ត៌មានមានលក្ខណៈសាមញ្ញងាយយល់ និងគួរកាត់បន្ថយការប្រើពាក្យបច្ចេកទេស និងពាក្យពេចន៍មានប្រើតែក្នុងជំនាញរបស់ខ្លួន ដែលអាចរាំងដល់ការប្រាស្រ័យទាក់ទងគ្នាបានច្បាស់លាស់ល្អ និងការបំផុសចំណាប់អារម្មណ៍។

***ការផ្តល់មតិទី៨៖*** ដើម្បីសម្រេចតាមគោលដៅភាពធន់នៃប្រព័ន្ធអ៊ិនធើណិត ការកំណត់តាំងពីដើមទីនូវរង្វាស់ជាក់លាក់ដោយមានការឯកភាពគ្នាពីអ្នកពាក់ព័ន្ធនានា អាចជួយពង្រឹងទំនុកចិត្តនិងការគាំទ្រដល់អ្នកចូលរួមទាំងឡាយ។ ក្នុងនេះ អង្គភាពទទួលបន្ទុកលើអភិបាលកិច្ចសន្តិសុខអ៊ិនធើណិត មានភារកិច្ចជំរុញឲ្យ អ្នកពាក់ព័ន្ធនានាអនុវត្តវិធីសាស្ត្រសកម្មឈានមុខ ដោយអាចប្រើប្រាស់លក្ខខ័ណ្ឌតម្រូវផ្សេងៗ និងបទបញ្ញត្តិស្តីពីសន្តិសុខអ៊ិនធើណិត ដើម្បីសម្រេចគោលដៅរបស់ខ្លួន។

***ការផ្តល់មតិទី៩៖*** ចំណេះដឹងជំនាញផ្នែកសន្តិសុខអ៊ិនធើណិតអាចកសាងឡើងបានតាមរយៈ សហប្រតិបត្តិការ និងការផ្លាស់ប្តូរបទពិសោធន៍គ្នា។ អាស៊ានបានជឿនលឿនទៅមុខច្រើនក្នុងការបង្កើត គំនិតផ្តួចផ្តើមផ្នែកអភិបាលកិច្ចសន្តិសុខអ៊ិនធើណិតក្នុងតំបន់ដែលកម្ពុជាអាចស្រង់យកមកប្រើប្រាស់បាន។ ជាក់ស្តែងកម្ពុជា គួរពិចារណាចូលរួមឲ្យបានខ្លាំងក្លាក្នុងមជ្ឈមណ្ឌលកសាងសមត្ថភាពសន្តិសុខអ៊ិនធើណិតអាស៊ាន-ជប៉ុន។ គោលដៅមួយរបស់មជ្ឈមណ្ឌលនេះគឺ បណ្តុះបណ្តាលអ្នកជំនាញការផ្នែកសន្តិសុខអ៊ិនធើណិតអាស៊ាន ក្នុងការការពារប្រព័ន្ធអ៊ិនធើណិត ការសិក្សាស្រាវជ្រាវលើកុំព្យូទ័រដែលរងគ្រោះថ្នាក់ និងការវិភាគកម្មវិធីកុំព្យូទ័រដែលបង្កផលអាក្រក់ (computer forensics and malware analysis) (JAIF 2018)។ ជំនាញទាំងនេះជួយដោះស្រាយដោយផ្ទាល់នូវ តម្រូវការផ្នែកបច្ចេកទេសក្នុងក្របខ័ណ្ឌសន្តិសុខអ៊ិនធើណិតរបស់ NIST និងតម្រូវការបណ្តុះបណ្តាលអ្នកវិជ្ជាជីវៈកម្ពុជាខាងផ្នែកសន្តិសុខអ៊ិនធើណិត ដែលមានជំនាញឯកទេសគ្រប់គ្រាន់។ កម្ពុជាក៏អាចប្រើកម្មវិធីបណ្តុះបណ្តាលនេះធ្វើជាគំរូមួយ ដើម្បីបង្កើតវគ្គសិក្សាពីសន្តិសុខអ៊ិនធើណិតរបស់ខ្លួនផ្ទាល់ សម្រាប់ដំណើរការនៅតាមសាកលវិទ្យាល័យ និងសម្រាប់កម្មវិធីអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ។

***ការផ្តល់មតិទី១០៖*** ការចេញលិខិតបញ្ជាក់គុណភាពសន្តិសុខអ៊ិនធើណិត ក៏អាចធ្វើឡើងសម្រាប់បុគ្គល និងអាជីវកម្មដែលមានជាស្រេចនូវ ចំណេះដឹងជំនាញផ្នែកសន្តិសុខអ៊ិនធើណិត និងបានប្រតិបត្តិតាមស្តង់ដាឧស្សាហកម្ម ដែលកំណត់ឡើងដោយរដ្ឋាភិបាល ឬ អង្គភាពកំណត់ស្តង់ដាឯកជននៅក្នុងតំបន់។ ឧស្សាហកម្មជាច្រើន បានប្រើប្រាស់បទបញ្ញត្តិរបស់ខ្លួនផ្ទាល់ ដើម្បីធ្វើការបញ្ជាក់គុណភាពនេះ ពីព្រោះអង្គភាពកំណត់ស្តង់ដាទាំងឡាយ អាចសម្របខ្លួនទៅនឹងបច្ចេកវិទ្យាថ្មីៗបានលឿនជាង និងការពារអ្នកប្រើប្រាស់បានល្អជាង បើធៀបទៅនឹងករណីដែលអង្គភាពទាំងនេះ ត្រូវពឹងផ្អែកទាំងស្រុងទៅលើដំណើរការរបស់រដ្ឋាភិបាល។ ឧទាហរណ៍ នៅសហរដ្ឋអាមេរិក ស្តង់ដាសន្តិសុខទិន្នន័យរបស់អាជីវកម្មផ្នែកប័ណ្ណទូទាត់ ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាអ្នកជំនាញការនៃផ្នែកអាជីវកម្មនេះ ដែលបានតម្រូវឲ្យក្រុមហ៊ុនប័ណ្ណឥណទាន (ឧ. VISA និង Mastercard) អនុវត្តតាមការត្រួតពិនិត្យសន្តិសុខ ដើម្បីកាត់បន្ថយការក្លែងបន្លំប័ណ្ណឥណទាន។ ការត្រួតពិនិត្យសន្តិសុខបន្ថែមទាំងនេះ មិនមែនគ្រាន់តែក្លាយជា បន្ទុកចំណាយបន្ថែមសម្រាប់អាជីវកម្មនោះទេ ប៉ុន្តែវាក៏ក្លាយជាកម្លាំងជម្រុញអាជីវកម្ម និងជាឧត្តមភាពប្រកួតប្រជែងមួយ តាមការពង្រឹងសន្តិសុខទិន្នន័យ និងការការពារឯកជនភាពរបស់អតិថិជននៃសាមីអាជីវកម្មផងដែរ។

## សេចក្តីសន្និដ្ឋាន

ចំនួនអ្នកប្រើអ៊ិនធើណិត និងឧបករណ៍ដែលមានការតភ្ជាប់នឹងប្រព័ន្ធអ៊ិនធើណិតនៅកម្ពុជា កំពុងកើនឡើងយ៉ាងលឿន ហើយអសកម្មភាព ក្នុងការកសាងក្របខ័ណ្ឌសន្តិសុខអភិបាលកិច្ចអ៊ិនធើណិតជាតិ អាចនាំឲ្យប្រជាជន និងសេដ្ឋកិច្ចកម្ពុជាជួបហានិភ័យធ្ងន់ធ្ងរមិនអាចទទួលយកបាន។ កិច្ចប្រឹងប្រែងគួរ

ចាប់ផ្ដើមពីថ្នាក់លើ ដោយក្រសួងមន្ទីរ និងអាជីវកម្មសំខាន់ៗទាំងអស់ ព្រមទាំងប្រជាពលរដ្ឋ ត្រូវចូលរួមយ៉ាងសកម្មដើម្បីញ៉ាំងឲ្យមានការសម្របសម្រួលល្អ និងលទ្ធផលប្រកបដោយចីរភាព។ ដើម្បីអាចមើលឃើញពី ហានិភ័យនៃការវាយប្រហារតាមអ៊ិនធើណិតទៅលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ រដ្ឋាភិបាលគួរពិចារណាកំណត់ឲ្យមន្ត្រីរបស់ខ្លួន និងម្ចាស់អាជីវកម្មពាក់ព័ន្ធបានទទួលការបណ្ដុះបណ្ដាល បង្កើនចំណេះដឹងពីសន្តិសុខអ៊ិនធើណិត ដើម្បីឲ្យមានការយល់ដឹងជាមូលដ្ឋាន អំពីការគំរាមកំហែងក្នុងវិស័យរៀងៗខ្លួន មុនពេលមានការដាក់អនុវត្តបទបញ្ញត្តិ ស្ដីពីសន្តិសុខអ៊ិនធើណិត ឬបទបញ្ញត្តិស្ដីពីបទល្មើសតាមអ៊ិនធើណិត។

នៅពេលរដ្ឋាភិបាលបានកំណត់ច្បាស់លាស់ហើយ នូវគោលដៅដែលខ្លួនចង់សម្រេចឲ្យបាន មន្ត្រីរដ្ឋាភិបាលគួររៀបចំគណៈកម្មាធិការចម្រុះមួយនៃស្ថាប័នរដ្ឋនិងឯកជន ដើម្បីកសាងបទបញ្ញត្តិស្ដីពី សន្តិសុខអ៊ិនធើណិតដែលផ្ដោតលើការការពារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅកម្ពុជា ក៏ដូចជាការទទួលស្គាល់ឯកជនភាពរបស់ពលរដ្ឋ នៅក្នុងអ៊ិនធើណិត ថាជាសិទ្ធិមនុស្សមួយផងដែរ។ គោលនយោបាយទាំងនេះ គួរលើកទឹកចិត្តអាជីវកម្មនានានៅកម្ពុជា ឲ្យសម្លឹងទៅរដ្ឋាភិបាលក្នុងការស្វែងរកធនធាន ដើម្បីពង្រឹងកម្មវិធីសន្តិសុខអ៊ិនធើណិតរបស់ខ្លួន។ កម្ពុជាបានរៀបចំរួចរាល់ហើយនូវ ក្រុមឆ្លើយតបបន្ទាន់នឹងបញ្ហាជាប់ទាក់ទងជាមួយនឹងកុំព្យូទ័រ ហើយក្រុមនេះគួរទទួលបាននូវធនធានមនុស្ស មូលនិធិ និងការបណ្ដុះបណ្ដាលបច្ចេកទេសដ៏ចាំបាច់ៗ ដើម្បីអាចក្លាយជាចំណុចកណ្ដាលសម្រាប់ឲ្យរដ្ឋាភិបាល និងអាជីវកម្មឯកជននានាស្វែងរកព័ត៌មានថ្មីទាន់ពេល និងព័ត៌មានសង្ខេបស្ដីពី ការគំរាមកំហែងលើសន្តិសុខ និងភាពងាយរងគ្រោះនៃប្រព័ន្ធអ៊ិនធើណិត។

ម្យ៉ាងទៀត រដ្ឋាភិបាលគួរពិចារណាធ្វើការវាយតម្លៃក្របខ័ណ្ឌសន្តិសុខអ៊ិនធើណិត NIST មួយ ដោយចាប់ផ្ដើមពីវិស័យអាចមានផលប៉ះពាល់ខ្លាំងជាងគេ ដូចជា ពាណិជ្ជកម្មអេឡិចត្រូនិក និងរដ្ឋាភិបាលអេឡិចត្រូនិក ជាដើម។ ពលរដ្ឋ និងអាជីវកម្មនានាកំពុងពឹងផ្អែកយ៉ាងលឿនទៅលើសេវាទាំងនេះ សម្រាប់ការធ្វើប្រតិបត្តិការធនាគារតាមអ៊ិនធើណិត ប្រតិបត្តិការពីអាជីវកម្មមួយទៅអាជីវកម្មមួយ ការបង់ថ្លៃទឹកនិងអគ្គិសនីតាមអ៊ិនធើណិត និងសេវាផ្សេងៗទៀត។ ការវាយតម្លៃសន្តិសុខអ៊ិនធើណិតតាមដំណាក់កាល អាចនាំឲ្យមានការកំណត់បានកាន់តែត្រឹមត្រូវនូវកាលបរិច្ឆេទសម្រេចគោលដៅ និងសហប្រតិបត្តិកាន់តែច្រើនទៀតរវាងក្រសួងនានា។

## ឯកសារយោង


Council of Councils. 2019. Ranking the Top Global Challenges. Report Card on International Cooperation. www.cfr.org/interactive/councilof councils/reportcard2019/#!/ranking/2019.

JAIF (Japan-ASEAN Integration Fund). 2018. "ASEAN-Japan Cybersecurity Capacity Building Centre (Step 2)." https://jaif.asean.org/support/project-brief/asean-japan-cybersecurity-capacity-building-centre.html.

Kepios Analysis. 2019. "Digital in Cambodia." https://datareportal.com/digital-in-cambodia.

NIST (National Institute of Standards and Technology). 2018. Framework for Improving Critical Infrastructure Cybersecurity. https://nvl pubs.nist.gov/nistpubs/CSWP/NIST.CSWP.041 62018.pdf.

Ou Phannarith. 2018. "Cybercrime and Legislation in Cambodia." Paper presented at the AFIN and Cybersecurity Workshop, Phnom Penh, Cambodia, 3 April 2018.

Republic of Singapore. 2018. Cybersecurity Act 2018.

RGC. 2014. Unofficial Draft of Cybercrime Law. https://www.ccimcambodia.org/wp-content/uploads/2014/10/draft_cybercrime_law_en.pdf

Seangly Phak. 2013. "'Developed' by 2050: PM." Phnom Penh Post, 7 Jun 2013. www. phnompenhpost. com/national/%E2%80%98dev eloped%E2%80%99-2050-pm.

World Bank. 2019. "Cambodia Annual GDP Growth." https://data.worldbank.org/indicator/NY.GDP.M KTP.KD.ZG?%20end=2018&locations=KH&most_recent_value_desc=true&start= 1994&view=chart.

# ការពិនិត្យឡើងវិញពីការអភិវឌ្ឍ និងអនុវត្ត ការអប់រំនិងបណ្ដុះបណ្ដាលផ្អែកលើសមត្ថភាព

## សេចក្ដីផ្ដើម

ការអប់រំផ្អែកលើលទ្ធផល ដែលជាប្រភពដើមនៃការអប់រំនិងបណ្ដុះបណ្ដាលផ្អែកលើសមត្ថភាព (CBET) មានប្រវត្តិជាច្រើនសតវត្សរ៍មកហើយ គឺចាប់តាំងពីរបៀបរបប ដូចជា សមាគមសិប្បករ ការហ្វឹកហាត់កូនជាង និង កម្មវិធីបណ្ដុះបណ្ដាលបច្ចេកទេសផ្សេងៗ (Nodine 2015)។ ទោះយ៉ាងនេះក្ដី CBET ជាផ្នែកមួយនៅក្មេងខ្ចី ដោយទើបផុសចេញពីកំណែទម្រង់ការអប់រំគ្រូបង្រៀនថ្នាក់បឋមសិក្សា និងវិជ្ជាជីវៈ នៅសហរដ្ឋអាមេរិកក្នុងទសវត្សរ៍១៩៧០ ប៉ុណ្ណោះ ដែលកាលនោះគេហៅថា ការអប់រំគ្រូបង្រៀនវិជ្ជាជីវៈផ្អែកលើលទ្ធផល (Deissinger and Hellwig 2005) ហើយមានអនុវត្តក្នុង ២៣រដ្ឋ។ បន្ទាប់មក CBET ក៏បានរីកដុះដាលជាបណ្ដើរៗក្នុងពិភពលោក ដោយមានការកែសម្រួលឲ្យស្របតាមបរិបទក្នុងស្រុក (Misbah, Gulikers and Mulder 2019)។

សរុបមក CBET គឺជា វិធីសាស្ត្រអនុវត្ត ការអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈផ្អែកលើលទ្ធផល ហើយសង្កត់ធ្ងន់លើសមត្ថភាពទាំងឡាយ ដែលមានតម្រូវការក្នុងទីផ្សារពលកម្ម ហើយតាមនេះអាចចូលរួមចំណែកយ៉ាងច្រើន និងដោយផ្ទាល់ក្នុងសេដ្ឋកិច្ច (Biemans, et al. 2004; Misbah et al. 2019) ។ ចំណុចនេះធ្វើឲ្យ CBET មានលក្ខណៈទាក់ទាញដល់ រដ្ឋាភិបាល អង្គការអន្តរជាតិ និងមជ្ឈដ្ឋានសិក្សាអប់រំជាច្រើនក្នុងពិភពលោក ជាពិសេសអ្នកធ្វើការខាងផ្នែក ឧត្ដមសិក្សា និង ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ។

អត្ថបទនេះ គឺជា ការពិនិត្យបូកសរុបឡើងវិញពីការអភិវឌ្ឍ និងអនុវត្ត CBET។ អត្ថបទនេះក៏មានធ្វើសំយោគនូវ ការសិក្សាស្រាវជ្រាវផ្សេងៗលើការអភិវឌ្ឍនិងអនុវត្តកម្មវិធីសិក្សា ដើម្បីជួយបំភ្លឺពីឫសគល់ក្នុងប្រវត្តិសាស្ត្រនៃក្របខ័ណ្ឌផ្សេងៗ ផ្ដោតលើ CBET ដែលអាចជាប់ទាក់ទងល្អ និងអនុវត្តបាននៅកម្ពុជា។

## អត្ថន័យនៃពាក្យ សមត្ថភាពរួម និង សមត្ថភាពជាក់លាក់

ដើម្បីអាចក្ដាប់បានថា CBET មានអ្វីខ្លះ ជាដំបូងគេត្រូវកំណត់និយមន័យពាក្យ សមត្ថភាពជារួម (competence) និង សមត្ថភាពជាក់លាក់ (competency)។ ថ្វីបើជារឿយៗគេប្រើពាក្យទាំងពីរនេះជំនួសគ្នាចុះឡើងក្ដី ប៉ុន្តែវាក៏អាចមានន័យខុសគ្នាដែរ។

- *សមត្ថភាពជារួម* សំដៅដល់ សមត្ថភាពសរុបរបស់បុគ្គល ហើយត្រូវបានកំណត់ថាជា ការគួបផ្សំ ចំណេះដឹង ជំនាញ និងឥរិយាបថនានា ដែលនាំឲ្យសម្រេចបានលទ្ធផលគ្រប់គ្រាន់នៅក្នុងមុខជំនាញ ឬកិច្ចការអ្វីមួយ។
- *សមត្ថភាពជាក់លាក់* (competency) សំដៅដល់ ជំនាញជាក់លាក់ និងអាចមើលឃើញ ដែលបុគ្គលត្រូវមានដើម្បីធ្វើការងារឲ្យបានល្អ (Brownie, Thomas and Bahnisch 2012)។

នៅក្នុងការសិក្សាខ្លះ គេប្រើតែពាក្យ សមត្ថភាពជារួម (competence) ខ្លះទៀតប្រើតែពាក្យ សមត្ថភាពជាក់លាក់ (competency) ហើយខ្លះទៀតប្រើពាក្យទាំងពីរដោយពុំមានការបែងចែកគ្នាឲ្យច្បាស់ឡើយ (ឧទាហរណ៍ Biemans, et al. 2004; Braun and Mishra 2016; Chapman and O'Neill 2010)។ សម្រាប់អត្ថបទនេះ អ្នកនិពន្ធប្រើតែពាក្យ "សមត្ថភាព" មួយប៉ុណ្ណោះ។

សមត្ថភាព តាមធម្មតាមានពីរប្រភេទ ពោលគឺ សមត្ថភាពតាមជំនាញជាក់លាក់ និង សមត្ថភាពទូទៅ ឬអាចផ្ទេរបាន។ សមត្ថភាពតាមជំនាញជាក់លាក់ គឺជា ជំនាញស្នូលដែលនិស្សិតត្រូវទទួលបានពីការសិក្សាអប់រំ ឬផ្នែកជំនាញវិជ្ជាជីវៈដោយឡែកណាមួយ រីឯ សមត្ថភាពទូទៅ វាមានលក្ខណៈអាចបត់បែនបានជាង និងអាចផ្ទេរបានយ៉ាងងាយ ពីផ្នែកជំនាញវិជ្ជាជីវៈណាមួយ ទៅផ្នែកជំនាញវិជ្ជាជីវៈមួយផ្សេងទៀត។ ឧទាហរណ៍ក្នុងកម្មវិធីសិក្សាផ្នែកវិស្វកម្ម ជំនាញវិស្វកម្ម គឺជា សមត្ថភាពតាមជំនាញវិជ្ជាជីវៈជាក់លាក់ រីឯជំនាញប្រាស្រ័យទាក់ទង និងជំនាញដោះស្រាយបញ្ហា គឺជា ជំនាញនិងសមត្ថភាពទូទៅដែលអាចយកទៅប្រើក្នុងការងារច្រើនបែបយ៉ាង។ ជាលទ្ធផលនៃការផ្លាស់ប្ដូរយ៉ាងលឿនខាងផ្នែកវិជ្ជាជីវៈ ដែលជំរុញឡើងដោយសារការរីកចម្រើនយ៉ាងលឿនផ្នែកបច្ចេកវិទ្យា ទីផ្សារពលកម្មក៏បានផ្លាស់ប្ដូរខ្លាំងណាស់ដែរ។ ដូច្នេះដើម្បីឆ្លើយតបទៅនឹង តម្រូវការនិងលក្ខខណ្ឌផ្សេងៗរបស់និយោជក និងទីផ្សារពលកម្ម និស្សិតនិងអ្នកមានសញ្ញាប័ត្រផ្នែកវិជ្ជាជីវៈ ត្រូវមានជំនាញនិងសមត្ថភាពមួយសំណុំធំ ដែលមានទាំង សមត្ថភាពតាមជំនាញវិជ្ជាជីវៈជាក់លាក់ និងសមត្ថភាពទូទៅ (Braun and Mishra 2016)។

## លក្ខណៈសំគាល់នៃ ការអប់រំ និងបណ្ដុះបណ្ដាលផ្អែកលើសមត្ថភាព (CBET)

ការអប់រំ CBET គេប្រើជាសំខាន់សម្រាប់ ការអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (VET)។ CBET មានផ្ដល់អត្ថប្រយោជន៍ជាច្រើន ដូចជា ជួយរៀបចំត្រៀមនិស្សិតសម្រាប់ទីផ្សារពលកម្ម

---

អត្ថបទនេះរៀបរៀងដោយ ជា សត្យា បេក្ខជនថ្នាក់បណ្ឌិត នៃសាកលវិទ្យាល័យអប់រំហុងកុង និង សុង សុភក្ដិ អ្នកស្រាវជ្រាវ និងប្រធានផ្នែកអប់រំ។ សូមយោងអត្ថបទនេះថា៖ Chea Sathya and Song Sopheak. 2019. “A Review of the Development and Implementation of Competency-Based Education and Training.” *Cambodia Development Review* vol 23, 2019: 7–11។

ជួយរក្សាទឹកចិត្តនិស្សិតឲ្យខិតខំរៀនសូត្រ និងទៅរៀនបានខ្ជាប់ខ្ជួនចប់វគ្គ (Deissinger and Hellwig 2005)។ លក្ខណៈសំគាល់ចម្បងមួយនៃ CBET គឺ ការផ្តោតលើសមត្ថភាព ជាជាងលើមុខវិជ្ជានៃការសិក្សា ដូចនៅក្នុងវិធីបង្រៀន និងរៀនសូត្រជាប្រពៃណី។ សមត្ថភាព សុទ្ធតែមានបង្កប់នៅក្នុងស្តង់ដាសមត្ថភាពនានាដែលតាមធម្មតាគឺ ក្រុមអ្នកជំនាញការផ្សេងៗ មកពីខាងសិក្សាអប់រំ អាជីវកម្ម និងឧស្សាហកម្មនានា បានកំណត់ឡើងយ៉ាងប្រយ័ត្នប្រយែង និងល្អិតល្អន់។ ក្នុងវិធីសាស្ត្រនេះ លទ្ធផលរំពឹងទុក ឬសមត្ថភាពផ្សេងៗ ក្នុងទម្រង់ជា ចំណេះដឹង ជំនាញ និងឥរិយាបថ មានចែងយ៉ាងច្បាស់ ដើម្បីធានាឲ្យខ្លឹមសារកម្មវិធីសិក្សា វាស៊ីគ្នាជាមួយនឹងស្តង់ដាសមត្ថភាពដែលគេបានកំណត់យក (Deissinger and Hellwig 2005)។

បណ្តាសមត្ថភាពជាគោលដៅនៃ CBET ទាប់ទាក់ដោយផ្ទាល់ទៅនឹងតម្រូវការទីផ្សារពលកម្ម ហើយកម្មវិធីសិក្សានៃ CBET រួមមាន ម៉ូឌុលផ្អែកលើលទ្ធផល ឬឯកតាសមត្ថភាព (performance-based modules or units of competency) ដែលអនុញ្ញាតឲ្យអ្នករៀនជំនាញវិជ្ជាជីវៈ អាចកសាងបានជាបណ្តើរៗនូវសមត្ថភាពជាប់ទាក់ទងផ្ទាល់នឹងតម្រូវការទីផ្សារពលកម្ម។ ទិដ្ឋភាពសំខាន់មួយទៀតនៃ CBET គឺ ការផ្តោតលើការរៀនសូត្របែបសាកពិសោធន៍ផ្អែកលើការអនុវត្តជាក់ស្តែង ដែលក្នុងនោះ និស្សិតរៀនសូត្រតាមរយៈ ពិភពពិតជាក់ស្តែង ស្ថានភាពសិប្បនិម្មិតសម្រាប់សាកពិសោធន៍ (simulation) និងសកម្មភាពក្នុងរោងជាង (Ordonez 2014)។ ការវាយតម្លៃលើនិស្សិត គឺផ្អែកលើសមត្ថភាពធ្វើការងារឲ្យបានជោគជ័យ។ នៅក្នុងថ្នាក់ CBET និស្សិតធ្វើការរៀនសូត្រតាមល្បឿនរបស់ខ្លួនផ្ទាល់ នៅក្នុងថ្នាក់រៀនមានសមត្ថភាពចម្រុះ ដែលអនុញ្ញាតឲ្យនិស្សិតអាចគ្រប់គ្រងនិងកំណត់ផ្លូវរៀនសូត្ររបស់ខ្លួនផ្ទាល់ ទៅតាមល្បឿន និងការយកចិត្តទុកដាក់របស់ខ្លួន ហើយតាមនេះអាចធានាបាននូវឱកាសសម្រាប់ការរៀនសូត្រឲ្យបានល្អបំផុត។

## ការអភិវឌ្ឍការអប់រំ និងបណ្តុះបណ្តាលផ្អែកលើសមត្ថភាព

ការកសាងកម្មវិធី CBET ចាប់ផ្តើមពីការ កំណត់និងជ្រើសរើសសមត្ថភាព និងការកំណត់ស្តង់ដាសមត្ថភាព (Deissinger and Hellwig, 2005)។ ស្តង់ដាសមត្ថភាពទាំងនេះ គឺជាសមាសធាតុស្នូលនៃ CBET ហើយសំខាន់បំផុតសម្រាប់ជួយតម្រែតម្រង់ការជ្រើសរើសឯកសារ និងបទពិសោធន៍សម្រាប់ ការបង្រៀននិងការរៀនសូត្រនៅក្នុងថ្នាក់រៀន ហើយក្រោយមកទៀត បានក្លាយជាលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃលទ្ធផល។ ស្តង់ដាសមត្ថភាព អាចបែងចែកជាបីប្រភេទ (Harris et al., as cited in Deissinger and Hellwig, 2005) គឺមាន៖

- *សមត្ថភាពឧស្សាហកម្ម* ដែលជា សមត្ថភាពដ៏ចាំបាច់ៗ សម្រាប់ឲ្យនិយោជិតបំពេញកិច្ចការរបស់ខ្លួនបានជោគជ័យ នៅក្នុងឧស្សាហកម្មជាក់លាក់ណាមួយ
- *សមត្ថភាពឆ្លងឧស្សាហកម្ម* ដែលជា សមត្ថភាពនានា អាចយកមកប្រើការបានក្នុងឧស្សាហកម្មលើសពីមួយមុខ
- *សមត្ថភាពសហគ្រាស* ដែលជា សមត្ថភាពនានា ត្រូវបានអភិវឌ្ឍ និងយកមកអនុវត្តសម្រាប់អង្គការ ឬក្រុមហ៊ុនជាក់លាក់ណាមួយ ហើយតាមធម្មតាតែងមាន ស្តង់ដាឧស្សាហកម្មកំណត់ច្បាស់។

វិធីដ៏មានប្រយោជន៍ពីរ ដែលមានប្រើជាទូទៅ សម្រាប់ការអភិវឌ្ឍស្តង់ដាសមត្ថភាព គឺ DACUM (Develop a Curriculum: ការអភិវឌ្ឍកម្មវិធីសិក្សា) និង ការវិភាគមុខងារ (functional analysis) (Deissinger and Hellwig 2005)។ DACUM រួមមាន ការកំណត់ជាប្រព័ន្ធនូវ កិច្ចការ ឬសមត្ថភាពនានាដែលផ្សារភ្ជាប់នឹងការងារ និងមុខរបរប្រភេទខ្លះ។ ស្រដៀងគ្នានឹងម៉ូដែលកម្មវិធីសិក្សាកម្រិតមូលដ្ឋានរបស់ Taba (1962) ដែលមានកម្មវត្ថុ ត្រូវបានជ្រើសរើសឡើងដោយផ្អែកលើ ការវិភាគពីតម្រូវការរបស់និស្សិត និងគ្រូបង្រៀននោះដែរ ក្នុងការវិភាគមុខរបរក្នុង DACUM អ្នកជំនាញការក្នុង មុខរបរកំពុងត្រូវបានលើកមកពីនិត្យណាមួយ តែងធ្វើការជាមួយទីប្រឹក្សាបច្ចេកទេស ដើម្បីកំណត់ ទំនួលខុសត្រូវចម្បងៗក្នុងការងារនោះ និងកិច្ចការជាកាតព្វកិច្ចទាំងឡាយ (Gonczi, Hager, and Oliver 1990)។

ផ្ទុយទៅវិញ ការវិភាគមុខងារ ដូចមានប្រើក្នុងក្នុងម៉ូដែលអភិវឌ្ឍកម្មវិធីសិក្សារបស់ Tyler (1949) ត្រូវបានធ្វើឡើងដោយអង្គភាពដែលគេបានទទួលស្គាល់ណាមួយ នៅក្នុងពាណិជ្ជកម្ម/ឧស្សាហកម្ម ដោយមានទីប្រឹក្សាម្នាក់ ជួយសម្របសម្រួល។ ក្នុងការវិភាគមុខងារ ពីដំបូងគេយកវិស័យមុខរបរទាំងមូលមួយមកពិនិត្យ បន្ទាប់មកគេបំបែកការងារផ្សេងៗ ទៅតាមវិស័យសេដ្ឋកិច្ច ហើយបន្ទាប់មកទៀត អង្គភាពតូចៗក្នុងទម្រង់ជាសមត្ថភាពត្រូវបានបំបែកចេញសម្រាប់ការងារនីមួយៗ (Gonczi, Hager, and Oliver 1990)។

ក្រោយពីបានកំណត់ស្តង់ដាសមត្ថភាពរួចហើយ សកម្មភាពរៀនសូត្រ និងវាយតម្លៃ ត្រូវបានកំណត់ឡើង មុនពេលធ្វើការជ្រើសរើសឯកសារ សម្រាប់ការរៀនសូត្រ។ ការគ្រប់គ្រងកម្មវិធីសិក្សាដើម្បីតាមដាន ការដាក់អនុវត្តកម្មវិធីសិក្សា ក៏សំខាន់ដូចគ្នាដែរ ។

## ការដាក់អនុវត្ត ការអប់រំ និងបណ្តុះបណ្តាលផ្អែកលើសមត្ថភាព

ការដាក់អនុវត្តកម្មវិធីសិក្សាថ្មី ជារឿយៗ តែងជួបការក្រាញរឹងរូស ដែលតាមធម្មតាផុសចេញពីក្តីបារម្ភអំពី ហិរញ្ញវត្ថុមិនគ្រប់គ្រាន់ អ្នកចូលរួមមានភាពជាម្ចាស់កម្រិតខ្សោយ កង្វះខាតអត្ថប្រយោជន៍ ជំនួយគាំទ្រផ្នែករដ្ឋបាលមិនមានប្រសិទ្ធភាព កំណើនបន្ទុកចំណាយរដ្ឋបាល និង អសន្តិសុខបង្កឡើងដោយការផ្លាស់ប្តូរភ្លាមៗ (Ornstein and Hunkins 2016)។ ដើម្បីលើកទឹកចិត្ត ឲ្យមានសហប្រតិបត្តិការកាន់តែច្រើន អ្នកអភិវឌ្ឍកម្មវិធីសិក្សាគួរចង្អុលបង្ហាញពី ផលចំណេញបានពីកម្មវិធីសិក្សាថ្មី ផលវិបាកនៃការមិនប្រតិបត្តិតាម និងលក្ខណៈដែលកម្មវិធីសិក្សាថ្មី វាស្រដៀងគ្នានឹងកម្មវិធីចាស់ ប៉ុន្តែល្អជាងច្រើន។ ការជំរុញការចូលរួមរបស់គ្រូបង្រៀននិងសាលារៀន ក្នុងដំណាក់កាលអភិវឌ្ឍន៍

កម្មវិធីសិក្សា ក៏ជាមធ្យោបាយមួយដើម្បីបង្កើនសហប្រតិបត្តិការក្នុងការដាក់អនុវត្តកម្មវិធីសិក្សាថ្មី ពីព្រោះវាជួយបង្កើនអារម្មណ៍ទទួលខុសត្រូវ និងភាពជាម្ចាស់។

ការដាក់អនុវត្តគំនិតផ្ដួចផ្ដើមលើ CBET អ្វីមួយ មិនខុសគ្នាអ្វីពីការដាក់អនុវត្តកម្មវិធីសិក្សាទូទៅនោះទេ។ យោងតាម Harris et al. ( 1995 cited in Deissinger and Hellwig, 2005 ) អ្នកអភិវឌ្ឍកម្មវិធី CBET គួរសួរក្នុងខ្លួនឯងនូវសំណួរសម្រាប់ពិចារណាមួយចំនួន មុននឹងរចនារៀបចំ និងដាក់អនុវត្តកម្មវិធី CBET។ សំណួរទាំងនេះជាប់ទាក់ទងនឹង ចំណេះដឹងរបស់ខ្លួន (តើខ្លួនឯងបានយល់ដឹង និងអាចពន្យល់ពី CBET បានច្បាស់ល្អប៉ុណ្ណា?) ជំនាញ (តើខ្លួនឯងអាចតម្រង់ទិសអ្នកឯទៀតទៅរក CBET, ធ្វើការរចនារៀបចំកម្មវិធី CBET, ផ្ដល់ជំនួយគាំទ្រ ដូចជា ឯកសារសម្រាប់រៀនសូត្រ ធនធាននិងគ្រឿងសម្រួលការផ្សេងៗ, និងកសាងនីតិវិធីសម្រាប់គ្រប់គ្រង CBET បានល្អប៉ុណ្ណា?) និងឥរិយាបថ (តើខ្លួនឯងមានទឹកចិត្តពុះពោរ មានការនឹងនរក្នុងចិត្ត និងមានអារម្មណ៍បើកទូលាយប៉ុណ្ណា ចំពោះទស្សនវិជ្ជា និងរបៀបរបបអនុវត្ត CBET?)។ សំណួរស្រដៀងគ្នាក៏គួរសាកសួរទៅអ្នកបង្រៀន CBET ផងដែរ ពោលគឺ ចំណេះដឹង (តើអ្នកបង្រៀនបានយល់ដឹងប៉ុណ្ណាពី CBET?) ជំនាញ (តើគាត់អាចអនុវត្តរបៀបរបបបង្រៀនបានល្អប៉ុណ្ណា ដើម្បីផ្ដល់ CBET ឲ្យបានប្រកបដោយប្រសិទ្ធភាព?) និង ឥរិយាបថ (តើគាត់មានអារម្មណ៍យ៉ាងណាពីទស្សនវិជ្ជា និងរបៀបរបបអនុវត្ត?)។

## បញ្ហាប្រឈមតាមធម្មតាក្នុងការដាក់អនុវត្ត

តាមពិត របៀបរបបអនុវត្ត CBET នៅតាមស្ថាប័ន TVET អាចជួបបញ្ហាប្រឈមជាច្រើន (Beimans et al. 2004)។ ដូច្នេះត្រូវមានការប្រយ័ត្នប្រយែងច្រើនណាស់ ដើម្បីក្ដាប់ឲ្យបានត្រឹមត្រូវនូវទិដ្ឋភាពផ្សេងៗនៃ សមត្ថភាពក្នុងមុខរបរ ព្រមទាំងភាពស្មុគស្មាញនៃកាតព្វកិច្ច និងកិច្ចការជាប់ទាក់ទិន។ ការពឹងផ្អែកខ្លាំងពេកលើការកំណត់ស្ដង់ដាសមត្ថភាព ក៏អាចប៉ះពាល់ដល់ភាពត្រឹមត្រូវនៃការវាយតម្លៃសមត្ថភាពដែរ ពីព្រោះស្ថាប័ន TVET នានា ជាអ្នកកំណត់ស្ដង់ដាទាំងនេះ ដែលអាចមិនសូវជាប់ទាក់ទងគ្នាល្អទៅនឹងតម្រូវការនៅក្នុងទីផ្សារពលកម្មសព្វថ្ងៃ (ការសិក្សាលើឯកសារបានគូសរំលេចតែពី តម្រូវការក្នុងប្រវត្តិសាស្រ្តប៉ុណ្ណោះ) ។

ការបន្សុីគ្នានូវការរៀនសូត្រក្នុងសាលារៀន ជាមួយនឹងការរៀនសូត្រនៅកន្លែងធ្វើការ និងការកែលំអវិធីសាស្រ្ត សម្រាប់បន្សុីលទ្ធផលអប់រំ និងបណ្ដុះបណ្ដាល ជាមួយនឹងតម្រូវការនៃទីផ្សារពលកម្ម គឺជាបញ្ហាសំខាន់ៗពីរទៀតដែលត្រូវដោះស្រាយ។ ក្នុងកិច្ចការនេះ អ្នកពាក់ព័ន្ធក្នុងការរចនារៀបចំសកម្មភាពរៀនសូត្រគួរធ្វើការវិភាគដោយប្រយ័ត្នប្រយែងពី បញ្ហាប្រឈមបន្ទាន់ៗទាំងនេះ។ ម្យ៉ាងទៀតឧបករណ៍វាយតម្លៃនានាត្រូវមានសុពលភាពអាចទុកចិត្តបាន អាចបត់បែនបាន និងមានយុត្តិធម៌ ហើយការវាយតម្លៃ ផ្អែកលើការចងចាំតាមបែបប្រពៃណី គួរតែបោះបង់ចោល ឬសើរើពិនិត្យឡើងវិញយ៉ាងច្រើន ដើម្បីអាចក្ដាប់បានពេញលេញនូវជំនាញ និងចំណេះដឹង ដែលនិស្សិតបានទទួល។

បញ្ហាប្រឈមមួយទៀតដែលរារាំងការទទួលយក CBET គឺការប្រែប្រួលក្នុងបរិស្ថានរៀនសូត្រ ជាពិសេសការផ្លាស់ប្ដូរក្នុងតួនាទី និងអត្តសញ្ញាណនៃគ្រូបង្រៀន។ ក្នុងវិធីសាស្រ្តបង្រៀនបែបប្រពៃណីដែលយកគ្រូធ្វើជាមជ្ឈមណ្ឌលនោះ តាមធម្មតាគេប្រើវិធីបង្រៀនតាមការពន្យល់មេរៀន ដែលក្នុងនោះ និស្សិតត្រូវស្ដាប់ការពន្យល់មេរៀនរបស់គ្រូ ដោយស្ងៀមស្ងាត់ ដោយមានអន្តរកម្មគ្រូ-និស្សិត ឬនិស្សិត-និស្សិតតិចតួចណាស់ ពោលគឺមានតែគ្រូប៉ុណ្ណោះ ដែលមានតួនាទីសកម្ម។ នៅក្នុងវិធីសាស្រ្តបង្រៀនបែបថ្មី គ្រូផ្លាស់ប្ដូរតួនាទីជាអ្នកជំនាញការក្នុងមុខវិជ្ជាដែលគាត់ផ្ទេរចំណេះដឹងទៅឲ្យនិស្សិតរបស់គាត់ ទៅជា អ្នកបង្ហាញផ្លូវ និងអ្នកសម្របសម្រួល ការរៀនសូត្ររបស់និស្សិត ជាអ្នកលើកទឹកចិត្តនិស្សិតឲ្យទទួលយកទំនួលខុសត្រូវ ដើម្បីចូលរួមសកម្មក្នុងការរៀនសូត្ររបស់ខ្លួនឯង។

ការគ្រប់គ្រងផ្អែកលើសមត្ថភាព ត្រូវដើរតួនាទីជាគំរូមួយសម្រាប់គ្រូបង្រៀន ហើយអ្នកគ្រប់គ្រងត្រូវជំរុញឲ្យមានវប្បធម៌បើកទូលាយ និងផ្ទត់គំនិតធ្វើសហប្រតិបត្តិការ ដើម្បីឲ្យគ្រូបង្រៀនអាចធ្វើជាម្ចាស់លើ ការគ្រប់គ្រងការបង្រៀន និងរៀនសូត្រ។ ការពិនិត្យឡើងវិញពីបញ្ហាផ្សេងៗ ដែលគេបានជួបក្នុងការទទួលយក CBET មិនមែនដើម្បីបន្ទុចបង្អាក់ការដាក់អនុវត្ត CBET នោះទេ។ ផ្ទុយទៅវិញ សារៈសំខាន់ដែលទទួលបានពីការដឹងស្គាល់នូវអន្លង់គ្រោះថ្នាក់ទាំងនេះ គឺថ្នាក់គ្រប់គ្រង និងគ្រូបង្រៀននៃស្ថាប័ន TVET នានា ត្រូវតែប្រយ័ត្នប្រយែង នៅពេលកសាងកម្មវិធីសិក្សា CBET និងក្នុងសកម្មភាពបង្រៀន និងរៀនសូត្រដើម្បីអាចទាញយកអត្ថប្រយោជន៍បានច្រើនជាអតិបរមា និងកាត់បន្ថយគុណវិបត្តិឲ្យនៅតិចបំផុត។

## ការរៀនសូត្រពីបទពិសោធន៍នៅអន្តរជាតិជាមួយ CBET

ក្នុងសាកលលោក កន្លងមកមានការដាក់អនុវត្ត CBET ដោយបានទទួលបទពិសោធន៍ និងលទ្ធផលជាច្រើន។ ការសិក្សាមួយធ្វើឡើងដោយ Misbah, Gulikers and Mulder (2019) ក្នុង ១១ សាលាមធ្យមសិក្សាវិជ្ជាជីវៈ ផ្នែកកសិកម្ម នៅឥណ្ឌូនេសុី បានរកឃើញថា ការដាក់អនុវត្ត CBET មានជោគជ័យក្នុងការអភិវឌ្ឍជំនាញ និងមានឥទ្ធិពល ជួយជំរុញទឹកចិត្តរបស់និស្សិត និងគ្រូបង្រៀន ប៉ុន្តែការអភិវឌ្ឍជំនាញនេះ បានប៉ះពាល់ដល់ការអភិវឌ្ឍចំណេះដឹង។

អ្នកស្រាវជ្រាវ Wang (2015) បានពិនិត្យពី ការយល់ឃើញរបស់និស្សិតអំពី CBET នៅក្នុងស្ថាប័នឧត្តមសិក្សាបី នៅអាមេរិកខាងជើង។ និស្សិតមានអារម្មណ៍ថា CBET បានផ្ដល់អត្ថប្រយោជន៍ចម្បងៗពីរ ពោលគឺ ១) ភាពជាប់ទាក់ទងកាន់តែល្អទៅនឹងទីផ្សារពលកម្ម បានពង្រឹងទំនុកចិត្តរបស់និស្សិតក្នុងការធ្វើផែនការ និងការត្រៀមរៀបចំសម្រាប់អាជីពរបស់ខ្លួន និង ២) វប្បធម៌រៀនសូត្រអាចបត់បែនបាន និងទៅតាមល្បឿនរបស់ខ្លួន បានអនុញ្ញាតឲ្យនិស្សិត អាចស្រូបយកបានយ៉ាងល្អនូវព័ត៌មាន និងជំនាញថ្មីៗ។ ប៉ុន្តែអត្ថប្រយោជន៍ទី២ សមស្របសម្រាប់តែនិស្សិតដែលមានទឹកចិត្តខ្លួនឯង ចង់រៀនសូត្រ និងដែលកំណត់

តារាងពេលរៀនសូត្ររបស់ខ្លួនឯងប៉ុណ្ណោះ។ ការបំផុសនិស្សិតឲ្យមានទឹកចិត្តរៀនសូត្រ អាចជាបញ្ហាប្រឈមចម្បងមួយសម្រាប់កម្មវិធី TVET នៅតាមប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងកម្មវិធី TVET នៅកម្ពុជា (ដែលមានកម្រិតស្មើគ្នានឹង ថ្នាក់ទី ១០ ១១ និង ១២ នៃវិទ្យាល័យចំណេះទូទៅ) និស្សិតភាគច្រើន ជាអ្នកបោះបង់ការសិក្សានៅមធ្យមសិក្សា ឬ មានការលំបាកក្នុងការរៀនសូត្រ ដូច្នេះទឹកចិត្ត និងជំនាញគ្រប់គ្រងខ្លួនឯងរបស់គាត់ ទំនងមានការខ្វះខាត។ ក្នុងស្ថានភាពនេះ គ្រូមានការលំបាកក្នុងការអនុញ្ញាតឲ្យនិស្សិតមានលទ្ធភាពអាចបត់បែនបាន ក្នុងការរៀនសូត្ររបស់ខ្លួន ពីព្រោះបើសិនគ្មានការជួយណែនាំ និងជំរុញទឹកចិត្តពីគ្រូបង្រៀននោះទេ និស្សិតទាំងនេះមិនអាចកំណត់របៀបរៀនសូត្រ និងប្រឹងរៀនសូត្រឲ្យបានល្អបំផុតនោះទេ។

កង្វះការរៀនសូត្រអាចបត់បែនបាន និងដឹកនាំដោយខ្លួនឯង ក៏មានគូសរំលេចដែរក្នុងការសិក្សាមួយស្ដីពី សាលា TVET មួយចំនួន (រួមមាន គ្រូបង្រៀន TVET និស្សិត អ្នកមានសញ្ញាប័ត្រ TVET ដែលបានការងារធ្វើ និងអ្នកត្រួតពិនិត្យការងារ) នៅប្រទេសអេត្យូពី (Solomon, 2016)។ ការសិក្សាបានរកឃើញថា CBET មិនបានអនុវត្តពេញលេញទេ ដោយសាលាខ្លះមានលក្ខណៈ "ផ្អែកលើសមត្ថភាពមួយភាគ" និងខ្លះទៀត "ផ្អែកលើសមត្ថភាពមួយភាគធំ"។ ការសិក្សាបានបង្ហាញទៀតថា មានទំនាក់ទំនងវិជ្ជមាន រវាងលក្ខណៈប្រកួតប្រជែងនៃកម្មវិធី TVET ជាមួយនឹង លទ្ធផលការងាររបស់អ្នកមានសញ្ញាប័ត្រ។

ការពិនិត្យឡើងវិញក្នុង ២០ឆ្នាំ នៃការបណ្ដុះបណ្ដាលផ្អែកលើសមត្ថភាព ក្នុងប្រព័ន្ធអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅអូស្ត្រាលី ដែលធ្វើឡើងដោយ Smith (2010) ក៏បានគូសរំលេចពីអត្ថប្រយោជន៍នៃ CBET ក្នុងការបង្កើនលទ្ធភាពរកបានការងារធ្វើរបស់អ្នកទទួលបានសញ្ញាប័ត្រ VET ដែរ ដោយសារមានកំណើនជំនាញអនុវត្តជាក់ស្ដែងជាប់ទាក់ទងនឹង តម្រូវការនៃទីផ្សារពលកម្ម ជាជាងកំណើនចំណេះដឹងផ្អែកទ្រឹស្ដី។ ប៉ុន្តែការសិក្សានេះ ក៏បានរកឃើញនូវបញ្ហាប្រឈមជាច្រើនជាប់ទាក់ទងនឹងការផ្ដល់ និងការវាយតម្លៃ CBET។ បញ្ហាមួយគឺ តម្លៃនៃពេលវេលា និងធនធានយ៉ាងច្រើន ដែលត្រូវចំណាយក្នុងការកសាងកញ្ចប់បណ្ដុះបណ្ដាលផ្សេងៗ។ បញ្ហាមួយទៀតគឺ កង្វះសមត្ថភាពគ្រូដើម្បីអនុវត្តតាមវិធីសាស្ត្រ CBET សុទ្ធសាធ ដែលត្រូវមានការយកនិស្សិតធ្វើជាមជ្ឈមណ្ឌល ក្នុងកម្រិតមួយយ៉ាងខ្ពស់ ការរៀនសូត្រអាចបត់បែនបាន និងតាមល្បឿនរបស់និស្សិត និង ការវាយតម្លៃជាទៀងទាត់ពី ការរីកចម្រើនរបស់និស្សិត និងលទ្ធផលសរុប។

## សេចក្ដីសន្និដ្ឋាន

ការពិនិត្យឡើងវិញពីឧបសគ្គផ្សេងៗ ដែលរារាំងការអនុវត្ត CBET ប្រកបដោយប្រសិទ្ធភាព បានផ្ដល់លទ្ធផលស្របគ្នានឹងសារៈសំខាន់នៅក្នុងឯកសារមានស្រាប់ស្ដីពី បញ្ហាប្រឈម និងអត្ថប្រយោជន៍សំខាន់ៗនៃ CBET។ អ្នកគ្រប់គ្រង និងគ្រូបង្រៀននៃស្ថាប័ន TVET នានា ត្រូវប្រយ័ត្នប្រយែងខ្លាំង នៅពេលធ្វើការអភិវឌ្ឍកម្មវិធី CBET និងសកម្មភាពបង្រៀន និងរៀនសូត្រ ដើម្បីអាចទាញយកអត្ថប្រយោជន៍ បានច្រើនជាអតិបរមា និងកាត់បន្ថយគុណវិបត្តិឲ្យនៅតិចបំផុត។

ការបង្រៀន និងការរៀនសូត្រ ដែលប្រើវិធីសាស្ត្រ យកនិស្សិតធ្វើជាមជ្ឈមណ្ឌល មានលក្ខណៈអាចបត់បែនបាន និងតាមល្បឿនរបស់និស្សិត អាចចោទបញ្ហានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ព្រោះនៅទីនោះ វិធីសាស្ត្រយកគ្រូធ្វើជាមជ្ឈមណ្ឌល និងពឹងផ្អែកលើការផ្ទេរចំណេះដឹង ការរៀនចាំមាត់ និងការអនុវត្តដដែលៗច្រើនសារ វានៅចាក់ឫសជ្រៅខ្លាំងណាស់។

ម្យ៉ាងទៀត ការដាក់អនុវត្ត CBET ក៏អាចចោទបញ្ហាដែរ បើសិនកម្មវិធីសិក្សាថ្មី គេមិនបានអភិវឌ្ឍ និងណែនាំបង្ហាញឲ្យបានត្រឹមត្រូវ។ វប្បធម៌របស់សាលារៀន ក៏ដើរតួនាទីសំខាន់បំផុតដែរក្នុងការដាក់អនុវត្តកម្មវិធីសិក្សា ហើយគ្រូបង្រៀនដែលជាអ្នកអនុវត្តកម្មវិធីសិក្សាដោយផ្ទាល់ ក៏សំខាន់ដូចគ្នា។ ក្នុងនេះ ការគ្រប់គ្រងផ្អែកលើសមត្ថភាព ត្រូវដើរតួនាទីជាគំរូ សម្រាប់គ្រូបង្រៀន។ អ្នកគ្រប់គ្រងសាលារៀន ត្រូវលើកទឹកចិត្តឲ្យមានវប្បធម៌បើកទូលាយ និងសហប្រតិបត្តិការ ដើម្បីឲ្យគ្រូបង្រៀនអាចប្រកាន់យកភាពជាម្ចាស់លើការបង្រៀន និងការរៀនសូត្រ។

កម្មវិធីសិក្សាដែលអង្គភាពថ្នាក់ជាតិ ទទួលបន្ទុកលើ CBET បានរចនារៀបចំឡើង គឺសាលារៀននីមួយៗ អាចយកមកកែសម្រួលទៅតាមបរិបទជាក់ស្ដែង ដើម្បីឲ្យបានស្របតាមវប្បធម៌របស់ខ្លួន ហើយគ្រូបង្រៀនជាបុគ្គល ឬជាក្រុម ក៏អាចកែសម្រួលវាទៅតាមស្ថានភាពខ្លួនដែរ។ បញ្ហានេះ អ្នកកសាងកម្មវិធីសិក្សាត្រូវតែយកមកពិចារណា នៅពេលធ្វើផែនការ និងដាក់អនុវត្តកម្មវិធីសិក្សាថ្មី ឬធ្វើការផ្លាស់ប្ដូរច្រើនៗក្នុងកម្មវិធីសិក្សា។

គ្រូបង្រៀន ត្រូវមានអារម្មណ៍ថា បានរង្វាន់អ្វីមួយ ពីការងាររបស់ខ្លួន។ សម្រាប់ការផ្លាស់ប្ដូរភ្លាមៗអ្វីមួយ គឺត្រូវតែមានការយល់ដឹងថា វាចាំបាច់ និងមានប្រយោជន៍ដល់គ្រូ និងនិស្សិត និងត្រូវមានការជួយសម្រួល តាមការផ្ដល់ជំនួយគាំទ្រ ផ្នែករដ្ឋបាលថវិកា និងបច្ចេកទេស ដល់គ្រូបង្រៀន។

## ឯកសារយោង


Biemans, Harm, Loek Nieuwenhuis, Rob Poell, Martin Mulder and Renate Wesselink. 2004. “Competence-Based VET in the Netherlands: Background and Pitfalls.” Journal of Vocational Education and Training 56 (4): 523–538.

Binkley, Marily, Ola Erstad, Joan Herman, Senta Raizen, Martin Ripley, May Miller-Ricci and Mike Rumble. 2012. “Defining Twenty-First Century Skills.” In Assessment and Teaching of

21st Century Skills, edited by Patrick Griffiin, Barry McGaw and Esther Care, 17–66. Dordrecht, Netherlands: Springer.

Braun, Edith, and Shweta Mishra. 2016. "Methods for Assessing Competences in Higher Education: A Comparative Review." In Theory and Method in Higher Education Research, edited by Jeroen Huisman and Malcom Tight, 47–68. Bingley, UK: Emerald Group.

Brownie, Sharn, Janelle Thomas and Mark Bahnisch. 2012. Exploring the Literature: Competency-Based Education and Training and Competency-Based Career Frameworks. Adelaide: University of Queensland Node of the Australian Health Workforce Institute in partnership with Health Workforce Australia.

Chapman, Elaine, and Marnie O'Neill. 2010. "Defining and Assessing Generic Competencies in Australian Universities: Ongoing Challenges." Education Research and Perspectives 37 (1): 105.

Deissinger, Thomas, and Silke Hellwig. 2005. Structures and Functions of Competence-based Education and Training (CBET): A Comparative Perspective. Mannheim, Germany: InWent (Capacity Building International).

Denham, Thomas J. 2002. Comparison of Two Curriculum/Instructional Design Models: Ralph W. Tyler and Siena College Accounting Class, ACCT205. eric.ed.gov/? id=ED4717340.

Gonczi, Andrew, Paul Hager and Liz Oliver. 1990. Establishing Competency-Based Standards in the Professions. Canberra: Australian Government Publishing Service.

Hunkins, Francis P., and Patricia A. Hammill. 1994. "Beyond Tyler and Taba: Reconceptualizing the Curriculum Process." Peabody Journal of Education 69 (3): 4–18.

Misbah, Zainun, Judith Gulikers and Martin Mulder. 2019. "Competence and Knowledge Development in Competence-Based Vocational Education in Indonesia." Learning Environments Research 22 (2): 253–274.

Nodine, T. R. 2016. "How Did We Get Here? A Brief History of Competency-Based Higher Education in the United States." Journal of Competency-Based Education 1 (1): 5–11.

Ordonez, B. 2014. "Competency-Based Education: Changing the Traditional College Degree Power, Policy, and Practice." New Horizons in Adult Education and Human Resource Development 26 (4): 47–53.

Ornstein, Allan C., Francis P. Hunkins. 2016. Curriculum: Foundations, Principles, and Issues. Seventh edition. Boston, MA: Pearson Education.

Parry, Scott B. 1996. "Just What is a Competency? (And Why Should You Care?)" Training 35 (6): 58–64.

Rychen, Domimique Simone and Laura Hersh Salganik, eds. 2003. Key Competencies for a Successful Life and a Well-Fujournal/websinctioning Society. Göttingen, Germany: Hogrefe & Huber.

Schilling, J. F., and J. R. Koetting. 2010. "Underpinnings of Competency-Based Education." Athletic Training Education Journal 5 (4): 165–169.

Shapiro, Joel. 2014. "Competency Based Degrees: Coming Soon to a Campus Near You. Chronicle of Higher Education." Chronicle of Higher Education, 17 Feb 2014. http://chronicle.com/article/Competency-Based-Degrees-/144769/.

Smith, Erica. 2010. "A Review of Twenty Years of Competency-Based Training in the Australian Vocational Education and Training System." International Journal of Training and Development 14 (1): 54–64.

Solomon, G. H. 2016. "Towards Competence-Based Technical-Vocational Education and Training in Ethiopia." Doctoral dissertation, Wageningen University, The Netherlands.

Taba, Hilda. 1962. Curriculum Development: Theory and Practice. New York: Harcourt, Brace & World.

Tyler, Ralph. 1949. Basic Principles of Curriculum and Instruction. Chicago, IL: University of Chicago Press.

United States Department of Education. 2017. Employability Skills Framework. http://cte.ed.gov/employabilityskills/.

Wang, Jennifer. 2015. "The Student Perspective on Competency-Based Education: Qualitative Research on Support, Skills, and Success. https://younginvincibles.org/wp-content/uploads/2015/10/Young-Invincibles-CBE-Paper.pdf.

World Economic Forum. 2016. The Future of Jobs: Employment, Skills and Workforce Strategy for the Fourth Industrial Revolution. Global Challenge Insight Report. http://www3.weforum.org/docs/WEF_Future_ of_Jobs.pdf.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះបង្ហាញពី សូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី ៣ ឆ្នាំ២០១៩។

ក្នុងចំណោម ៦ប្រទេសអាស៊ានជ្រើសរើស មានតែវៀតណាម មួយប៉ុណ្ណោះដែលមាន កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ កើនដល់ ៧,៣% ធៀបនឹង ៦,៩% នៅត្រីមាសទី៣ ឆ្នាំ២០១៨។ សេដ្ឋកិច្ចឥណ្ឌូនេស៊ី មានស្ថិរភាព ដោយមានកំណើន ផសស ដល់ ៥,០% នៅត្រីមាសទី២ និង ទី៣ ឆ្នាំ២០១៩ ប៉ុន្តែ កំណើននេះធ្លាក់ចុះ ០,១ឯកតាភាគរយ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ និងធ្លាក់ចុះ ០,២ឯកតាភាគរយ ធៀបនឹងត្រីមាស ទី៣ និងទី៤ ឆ្នាំ២០១៨។ កំណើននៅម៉ាឡេស៊ី ធ្លាក់ចុះ ០,៣ឯកតាភាគរយ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៨, ធ្លាក់ចុះ ០,១ឯកតាភាគរយ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ និង ធ្លាក់ចុះ ០,៥ឯកតាភាគរយ ធៀបនឹងត្រីមាសទី២។ សេដ្ឋកិច្ចសិង្ហបុរី ងើបឡើងវិញបាន ០,៤ឯកតាភាគរយ ធៀបនឹងត្រីមាសមុន ដែលមានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ធ្លាក់ចុះដល់ ០,១% (៣,៩%នៅត្រីមាសទី២ ឆ្នាំ២០១៨) ប៉ុន្តែបើធៀបនឹងកាលពី មួយឆ្នាំមុន វាបានធ្លាក់ចុះអស់ ១,៧ឯកតាភាគរយ។ ផសស ថៃ កើនដល់ ២,៤% ឬកើន ០,១ឯកតាភាគរយធៀបនឹងត្រីមាសមុន ក្រោយបានរួមចុះនៅត្រីមាសទី១ និង ទី២ ឆ្នាំ២០១៩ បើធៀប នឹងត្រីមាសទី៤ ឆ្នាំ២០១៨ ដែលមានកំណើនដល់ ៣,៧%។

ក្នុងចំណោមសេដ្ឋកិច្ចជ្រើសរើសទាំងបួននៅអាស៊ី ចិនមាន អត្រាកំណើនខ្ពស់ជាងគេ ដល់ ៦,០% ប៉ុន្តែកំណើននេះបាន ធ្លាក់ចុះអស់ ០,២ឯកតាភាគរយ ធៀបនឹងត្រីមាសមុន។ អត្រា កំណើនមានដល់ ២,៩% នៅហុងកុង, ២,០% នៅកូរ៉េខាងត្បូង, និង ៣,០% នៅតៃវ៉ាន់។ បើពិនិត្យក្នុងរយៈពេលវែង កំណើន ផសស ពិត នៅចិន បានធ្លាក់ចុះអស់ ៨ត្រីមាសបន្តបន្ទាប់ តាំងពីកំណើន ៦,៩% នៅឆ្នាំ២០១៧។ កំណើននៅហុងកុង បានងើបឡើងវិញដល់ ២,៩% គឺដល់កម្រិតនៅត្រីមាសទី៣ ឆ្នាំ២០១៨ ក្រោយបានរួមចុះអស់ ៣ត្រីមាសបន្តបន្ទាប់។ កំណើន នៅកូរ៉េខាងត្បូង បានរួមចុះអស់ ០,១ឯកតាភាគរយ ធៀបនឹង ត្រីមាសមុន ក្រោយបានស្ទុះឡើងពីកម្រិតទាបបំផុតត្រឹម ១,៨% នៅត្រីមាសទី១ ឆ្នាំ២០១៩។ តៃវ៉ាន់មានកំណើនសេដ្ឋកិច្ចដល់ ៣,០% ដែលជាអត្រាខ្ពស់បំផុតលំដាប់ទី២ គិតតាំងពីត្រីមាសទី២ ឆ្នាំ២០១៨ ដែលមានកំណើនដល់ ៣,៣%។

កំណើន ផសស ពិត នៅតំបន់អឺរ៉ូ១២ បានឡើងចុះក្នុងចន្លោះ ពី ១,១% ដល់ ១,២% ក្នុង ៤ត្រីមាសចុងក្រោយនេះ ដែល បង្ហាញពីការធ្លាក់ចុះកំណើនអស់ ១,៣ឯកតាភាគរយ, ១,០ឯកតា ភាគរយ និង ០,៤ឯកតាភាគរយ ធៀបនឹង ត្រីមាសទី១ ទី២ និង ទី៣ ឆ្នាំ២០១៨។ កំណើន ផសស ពិត នៅជប៉ុន កើនឡើង ជាទៀងទាត់ដល់ ១,៧% ធៀបនឹងកម្រិតទាបបំផុតត្រឹម ០,០% នៅត្រីមាសទី៣ ឆ្នាំ២០១៨។ កំណើន ផសស ពិត នៅសហរដ្ឋ អាមេរិក ធ្លាក់ចុះមកត្រឹម ២,១% ដែលកំណើនប្រចាំត្រីមាស ទាបបំផុត គិតតាំងពីត្រីមាសទី១ ឆ្នាំ២០១៨ ដោយបាន ធ្លាក់ចុះអស់ ១,១ឯកតាភាគរយ ធៀបនឹងកម្រិតខ្ពស់បំផុតក្នុង រយៈពេល ៧ត្រីមាសនេះ ឬស្មើគ្នានឹងកំណើន ផសស ជាមធ្យម ក្នុងឆ្នាំ២០១៣។

**អតិផរណាក្នុងពិភពលោក**

អត្រាអតិផរណាក្នុង ៦ប្រទេសអាស៊ានជ្រើសរើស មិនមាន ការប្រែប្រួលដូចគ្នាទេ។ អតិផរណាបានកើនឡើងនៅ កម្ពុជា ឥណ្ឌូនេស៊ី និង ម៉ាឡេស៊ី ប៉ុន្តែថយចុះនៅ សិង្ហបុរី ថៃ និង វៀតណាម។ នៅកម្ពុជា អតិផរណាកើនដល់ ២,០% គឺកើនត្រឹម ០,២ឯកតាភាគរយ ធៀបនឹង ត្រីមាសទី២ ដែលមានអត្រា អតិផរណាទាបបំផុតក្នុងរយៈពេល ៧ត្រីមាសនេះ។ ឥណ្ឌូនេស៊ី មានអត្រាអតិផរណាខ្ពស់ជាងគេក្នុង ៣ត្រីមាសចុងក្រោយ ដោយ កើនដល់ ៣,៤% នៅត្រីមាសទី៣ ដែលជាអត្រាអតិផរណា ខ្ពស់បំផុតក្នុង រយៈពេល ៧ត្រីមាស គិតតាំងពីត្រីមាសទី១ ឆ្នាំ២០១៨ មក។ អតិផរណានៅម៉ាឡេស៊ី ឡើងដល់ ១,៣% គឺកើន ០,៧ឯកតាភាគរយ ធៀបនឹង ត្រីមាសទី២ ដែលមានត្រឹម ០,៦% និង ត្រីមាសទី១ ដែលមានបរិត្តផរណាដល់ ០,៣%។ នៅសិង្ហបុរី អត្រាអតិផរណាធ្លាក់ចុះដល់ ០,៥% ធៀបនឹង ០,៨% នៅត្រីមាសទី២ ប៉ុន្តែស្មើគ្នានឹង អត្រាអតិផរណានៅត្រីមាសទី១ ឆ្នាំ២០១៩ និង ត្រីមាសទី៤ ឆ្នាំ២០១៨។ គួរកត់សំគាល់ថា ក្នុងចំណោមប្រទេសអាស៊ាននានា សិង្ហបុរីមានអត្រាអតិផរណា ទាបជាងគេ បន្ទាប់មកគឺ ថៃដែលមានអត្រាធ្លាក់ចុះដល់ ០,៦% ឬ ធ្លាក់ចុះអស់ ០,៥ឯកតាភាគរយ ធៀបនឹង ត្រីមាសទី២ ដែល មានអតិផរណារហូតដល់ ១,១% ឬអត្រាខ្ពស់បំផុតក្នុងរយៈពេល ៤ត្រីមាស។ អតិផរណានៅវៀតណាម ចុះដល់ ២,២% ឬធ្លាក់ចុះ ០,៥ឯកតាភាគរយ ធៀបនឹង ត្រីមាសទី២ និងធ្លាក់ចុះ រហូតដល់ ២,៣ឯកតាភាគរយ ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០១៨ ដែលមានអត្រាអតិផរណារហូតដល់ ៤,៥% គឺខ្ពស់ជាងប្រទេស ជ្រើសរើសឯទៀតទាំងអស់ ក្នុងរយៈពេល ៧ត្រីមាសចុងក្រោយ។

អតិផរណានៅចិន ឡើងដល់ ២,៩% ឬកើន ០,៣ឯកតា ភាគរយ ធៀបនឹងត្រីមាសមុន, នៅហុងកុង វាកើន ០,៧ឯកតា ភាគរយ រហូតដល់ ៣,៤% ដែលជាអត្រាអតិផរណាខ្ពស់បំផុតនៅ ហុងកុង គិតតាំងពីឆ្នាំ២០១៥ មក និងជាអត្រាខ្ពស់ជាងគេនៅ ប្រទេសអាស៊ីជ្រើសរើសទាំងអស់ក្នុងរយៈពេលដូចគ្នា។ អតិផរណា នៅកូរ៉េខាងត្បូង មាននិន្នាការធ្លាក់ចុះជាទៀងទាត់ គិតតាំងពី ត្រីមាសទី៣ ឆ្នាំ២០១៨ មក ដោយធ្លាក់ចុះរហូតដល់ ០,១% នៅត្រីមាសទី៣ ឆ្នាំ២០១៩ (ធ្លាក់ចុះអស់ ០,៦ឯកតាភាគរយ

---

អត្ថបទនេះ រៀបរៀងដោយលោក ភឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

ធៀបនឹងត្រីមាសមុន) ពោលគឺ ដល់កម្រិតទាបបំផុតគិតតាំងពីឆ្នាំ២០១៣ មក និងជាអត្រាអតិផរណាទាបជាងគេក្នុងចំណោមប្រទេសអាស៊ីជ្រើសរើសទាំងអស់ក្នុងរយៈពេលដូចគ្នា។ អតិផរណានៅតៃវ៉ាន់ បានឡើងចុះក្នុង ៤ត្រីមាសចុងក្រោយ ដោយនៅថេរត្រឹម ១,៦% បាន ៣ត្រីមាសបន្តបន្ទាប់ រហូតដល់ត្រីមាសទី៣ ឆ្នាំ២០១៨ ហើយនៅត្រីមាសទី៣ ឆ្នាំ២០១៩ នេះ វាចុះដល់ ០,៤% ធៀបនឹង ០,៨% នៅត្រីមាសមុន។

ក្នុងចំណោមប្រទេសឧស្សាហកម្មជ្រើសរើសនានា ជប៉ុនមានអត្រាអតិផរណាទាបជាងគេ គិតតាំងពីឆ្នាំ២០១៦ មក។ នៅត្រីមាសទី៣ ឆ្នាំ២០១៩ នេះ ជប៉ុនមានអត្រាអតិផរណា ០,៣% ឬធ្លាក់ចុះអស់ ០,៤ឯកតាភាគរយ ធៀបនឹងត្រីមាសមុន (០,៧%)។ នៅតំបន់អឺរ៉ូ១២ និងសហរដ្ឋអាមេរិក អត្រាអតិផរណាមាននិន្នាការស្រដៀងគ្នាក្នុង ៧ត្រីមាសចុងក្រោយ។ ធៀបនឹងត្រីមាសមុន អតិផរណានៅតំបន់អឺរ៉ូ១២ ធ្លាក់ចុះអស់ ០,៤ឯកតាភាគរយ ដល់ ១,០% ដែលជាអត្រាទាបបំផុតគិតតាំងពីឆ្នាំ២០១៧ មក ហើយនៅសហរដ្ឋអាមេរិក វាធ្លាក់ចុះអស់ ០,១ឯកតាភាគរយ ដល់ ១,៧% គឺស្មើគ្នានឹងត្រីមាសទី១ ឆ្នាំ២០១៩ និងជិតស្មើគ្នានឹងឆ្នាំ២០១៤ ។

## អត្រាប្តូរប្រាក់

ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលបានចុះថ្លៃដល់ ៤.០៨៦,៨ រៀល/ដុល្លារ ធៀបនឹង ៤.០៥២,១រៀល/ដុល្លារ នៅត្រីមាសទី២ និង ៤.០០៦,៦រៀល/ដុល្លារនៅត្រីមាសទី១។ ដុល្លារសិង្ហបុរីមានស្ថិរភាពនៅកម្រិត ១,៤ដុល្លារសិង្ហបុរី/ដុល្លារអាមេរិក គិតតាំងពីត្រីមាសទី៣ ឆ្នាំ២០១៨ មក ក្រោយបានចុះថ្លៃពីកម្រិត ១,៣ដុល្លារសិង្ហបុរី/ដុល្លារអាមេរិក នៅត្រីមាសទី១ និង ទី២ ឆ្នាំ២០១៨។ ប្រាក់បាតថៃ បានឡើងថ្លៃដល់ ៣០,៧បាត/ដុល្លារ ដោយបាននៅថេរត្រឹម ៣១,៦បាត/ដុល្លារ ក្នុង ២ត្រីមាសមុន។ ប្រាក់ដុងវៀតណាម បានចុះថ្លៃដល់ ២៣.២៥៨,៣ដុង/ដុល្លារ ដោយមាននិន្នាការបន្តចុះថ្លៃតាំងពីកម្រិត ២២.៤៨៣,៩ដុង/ដុល្លារ នៅត្រីមាសទី២ ឆ្នាំ២០១៨ មក។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ធៀបនឹងត្រីមាសទី២ ឆ្នាំ២០១៩ ប្រេងដូងប្រេង និងអង្ករ បានឡើងថ្លៃ រីឯ ពោត កៅស៊ូ សណ្ដែកសៀង ប្រេងឆៅ សាំង និង ម៉ាស៊ូត បានចុះថ្លៃ។ ប្រេងដូងប្រេងបានឡើងថ្លៃ ០,៤% ហើយអង្ករឡើងថ្លៃ ២,៣% រីឯពោតបានចុះថ្លៃ ៣,៣%, កៅស៊ូចុះថ្លៃ ១០,៣%, សណ្ដែកសៀងចុះថ្លៃ ២,៣%, ប្រេងឆៅចុះថ្លៃ ៨,៣%, សាំងចុះថ្លៃ ៦,៩% ហើយ ម៉ាស៊ូតចុះថ្លៃ ៤,៣%។ ធៀបនឹងកាលពីមួយឆ្នាំមុន ពោតឡើងថ្លៃ ៧,៧%, កៅស៊ូឡើងថ្លៃ ១,៨% ហើយអង្ករឡើងថ្លៃ ៣,៥% រីឯ ប្រេងដូងប្រេងចុះថ្លៃ ៦,៨%, សណ្ដែកសៀងចុះថ្លៃ ១៣,០%, ប្រេងឆៅចុះថ្លៃ ១៩,៥%, សាំងចុះថ្លៃ ១៥,០% ហើយ ម៉ាស៊ូតចុះថ្លៃ ១៣,៦%។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៣-២០១៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.3 | 7.1 | 7.0 | 7.0 | 7.0 | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.3 | 5.2 | 4.8 | 5.0 | 5.1 | 5.1 | 5.3 | 5.2 | 5.2 | 5.1 | 5.0 | 5.0 |
| ម៉ាឡេស៊ី | 5.4 | 6.0 | 4.9 | 4.3 | 5.9 | 5.4 | 4.5 | 4.4 | 4.7 | 4.5 | 4.9 | 4.4 |
| សិង្ហបុរី | 1.3 | 3.0 | 2.0 | 2.0 | 3.8 | 4.4 | 3.9 | 2.2 | 2.2 | 1.3 | 0.1 | 0.5 |
| ថៃ | 6.8 | 1.6 | 2.8 | 3.2 | 3.8 | 4.8 | 4.6 | 3.3 | 3.7 | 2.8 | 2.3 | 2.4 |
| វៀតណាម | 5.2 | 5.9 | 6.6 | 6.1 | 6.6 | 7.4 | 6.8 | 6.9 | 7.6 | 6.8 | 6.7 | 7.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.8 | 7.3 | 7.0 | 6.7 | 6.9 | 6.8 | 6.7 | 6.5 | 6.4 | 6.4 | 6.2 | 6.0 |
| ហុងកុង | 2.9 | 2.3 | 2.3 | 1.7 | 2.8 | 4.7 | 3.5 | 2.9 | 1.3 | 0.6 | 0.5 | 2.9 |
| កូរ៉េខាងត្បូង | 2.1 | 3.4 | 2.6 | 2.6 | 3.0 | 2.8 | 2.9 | 3.2 | 3.2 | 1.8 | 2.1 | 2.0 |
| តៃវ៉ាន់ | 1.2 | 3.5 | 0.6 | 1.2 | 2.8 | 3.0 | 3.3 | 2.3 | 1.8 | 1.7 | 2.4 | 3.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | -0.5 | 0.7 | 1.3 | 1.6 | 2.3 | 2.5 | 2.2 | 1.6 | 1.1 | 1.2 | 1.1 | 1.2 |
| ជប៉ុន | 1.7 | 0.6 | 0.3 | 0.9 | 1.8 | 1.1 | 1.0 | 0 | 0.4 | 0.9 | 1.2 | 1.7 |
| សហរដ្ឋអាមេរិក | 2.1 | 2.4 | 2.3 | 1.6 | 2.3 | 2.8 | 2.9 | 3.0 | 3.1 | 3.2 | 2.3 | 2.1 |

Sources: International Monetary Fund; *Economist*; countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៣-២០១៩ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.0 | 3.9 | 1.2 | 3.0 | 2.9 | 2.2 | 2.7 | 2.5 | 2.4 | 1.9 | 1.8 | 2.0 |
| ឥណ្ឌូនេស៊ី | 7.0 | 6.4 | 6.4 | 3.5 | 3.8 | 3.3 | 3.2 | 3.1 | 3.2 | 2.6 | 3.1 | 3.4 |
| ម៉ាឡេស៊ី | 2.1 | 3.2 | 2.1 | 2.1 | 3.9 | 1.8 | 1.3 | 0.4 | 0.3 | -0.3 | 0.6 | 1.3 |
| សិង្ហបុរី | 2.3 | 1.0 | -0.5 | -0.8 | 0.6 | 0.2 | 0.4 | 0.7 | 0.5 | 0.5 | 0.8 | 0.5 |
| ថៃ | 2.2 | 1.9 | -0.9 | 0.2 | 0.7 | 0.6 | 1.3 | 1.5 | 0.8 | 0.7 | 1.1 | 0.6 |
| វៀតណាម | 6.6 | 4.8 | 0.6 | 2.7 | 3.4 | 2.8 | 3.8 | 4.5 | 3.4 | 2.6 | 2.7 | 2.2 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.6 | 2.0 | 1.4 | 2.0 | 1.6 | 2.2 | 1.8 | 2.3 | 2.2 | 1.8 | 2.6 | 2.9 |
| ហុងកុង | 4.0 | 4.4 | 3.1 | 2.5 | 1.7 | 2.4 | 2.1 | 2.3 | 2.6 | 2.2 | 2.7 | 3.4 |
| កូរ៉េខាងត្បូង | 1.1 | 1.3 | 0.7 | 0.8 | 2.0 | 1.2 | 1.5 | 1.6 | 1.2 | 0.6 | 0.7 | 0.1 |
| តៃវ៉ាន់ | 0.8 | 1.5 | 0.6 | 1.4 | 0.6 | 1.6 | 1.6 | 1.6 | 0.9 | 0.3 | 0.8 | 0.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.4 | 0.0 | 0.3 | 1.5 | 1.3 | 1.7 | 2.1 | 1.9 | 1.4 | 1.4 | 1.0 |
| ជប៉ុន | 0.4 | 2.8 | 0.9 | -0.1 | 0.6 | 1.3 | 0.6 | 1.1 | 0.9 | 0.3 | 0.7 | 0.3 |
| សហរដ្ឋអាមេរិក | 1.5 | 1.6 | 0.0 | 1.2 | 2.1 | 2.2 | 2.7 | 2.6 | 2.2 | 1.7 | 1.8 | 1.7 |

Sources: International Monetary Fund; *Economist*; National Institute of Statistics

តារាង៣៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៣-២០១៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4027.2 | 4037.6 | 4060.4 | 4053.6 | 4047.0 | 4012.4 | 4047.0 | 4073.7 | 4046.7 | 4006.6 | 4052.1 | 4086.8 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10419.2 | 11850.2 | 13394.8 | 13338.3 | 13379.8 | 13576.1 | 13944.6 | 14600.2 | 14789.7 | 14127.8 | 14246.8 | 14117.6 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.1 | 3.3 | 3.9 | 4.1 | 4.3 | 3.9 | 3.9 | 4.1 | 4.2 | 4.1 | 4.1 | 4.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 30.7 | 32.5 | 34.2 | 35.3 | 33.9 | 31.6 | 31.9 | 33.0 | 32.8 | 31.6 | 31.6 | 30.7 |
| វៀតណាម (ដុង) | 20990.3 | 21138.2 | 21917.7 | 22507.5 | 22645.9 | 22749.5 | 22483.9 | 22675.7 | 22744.1 | 22902.9 | 23255.5 | 23258.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.1 | 6.2 | 6.3 | 6.6 | 6.8 | 6.4 | 6.4 | 6.8 | 6.9 | 6.7 | 6.8 | 7.0 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1095.0 | 1053.6 | 1131.9 | 1161.0 | 1130.5 | 1072.0 | 1079.0 | 1120.9 | 1127.7 | 1125.0 | 1165.4 | 1193.4 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 29.7 | 30.3 | 31.8 | 32.3 | 30.4 | 29.3 | 29.8 | 30.7 | 30.8 | 30.8 | 31.1 | 31.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 97.6 | 105.9 | 121.0 | 108.8 | 112.1 | 108.4 | 109.1 | 111.4 | 112.8 | 110.1 | 109.9 | 107.3 |

Sources: International Monetary Fund; *Economist*; National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១៣-២០១៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 259.4 | 192.9 | 169.8 | 159.2 | 154.5 | 163.7 | 173.3 | 157.9 | 162.8 | 167.5 | 175.9 | 170.1 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 856.9 | 821.4 | 622.7 | 643.6 | 714.7 | 673.7 | 601.0 | 612.0 | 554.8 | 586.9 | 568.1 | 570.1 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 2575.3 | 1755.6 | 1392.7 | 1416.1 | 1688.3 | 1504.0 | 1433.3 | 1365.2 | 1303.1 | 1436.6 | 1549.5 | 1389.7 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 533.8 | 434.9 | 395.5 | 406.7 | 452.3 | 459.3 | 451.0 | 424.7 | 426.7 | 426.7 | 430.0 | 439.7 |
| សណ្តែកសៀង (US No.1) - USA (ដុល្លារ/តោន) | 538.4 | 491.8 | 390.4 | 405.7 | 400.6 | 418.3 | 435.6 | 390.6 | 368.9 | 353.3 | 347.8 | 339.7 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 105.9 | 96.2 | 49.6 | 40.7 | 52.6 | 64.7 | 71.9 | 74.2 | 67.2 | 63.0 | 65.1 | 59.7 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 71.2 | 65.6 | 41.0 | 35.2 | 42.4 | 47.9 | 53.3 | 54.1 | 42.9 | 40.9 | 49.4 | 46.0 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 78.4 | 71.5 | 41.7 | 34.8 | 42.9 | 51.0 | 55.6 | 56.6 | 52.2 | 49.5 | 51.1 | 48.9 |

Sources: Food and Agriculture Organisation; US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុង ៤ត្រីមាសចុងក្រោយនេះ មានការប្រែប្រួលគួរឲ្យកត់សំគាល់ក្នុង វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ដែលត្រូវបានអនុម័ត។ នៅត្រីមាសទី៣ ឆ្នាំ២០១៩ ការអនុម័តលើគម្រោងវិនិយោគសរុប កើន ៨,៩% ពីមួយឆ្នាំទៅមួយឆ្នាំ ដល់ ១.១៥៣,៥លានដុល្លារ ប៉ុន្តែតួលេខនេះបង្ហាញពីការធ្លាក់ចុះ ៥៧,០% និង ៤០,៤% ធៀបនឹងត្រីមាសទី២ និងត្រីមាសទី១ រៀងគ្នា។ គិតតាមវិស័យ ការអនុម័តវិនិយោគផ្នែកសេវាកម្ម កើន ៤០,៣% គឺជំរុញឡើងដោយសារ ការអនុម័តវិនិយោគលើសណ្ឋាគារនិងទេសចរណ៍ដែលកើន ១០,៨% ដល់ ៨០៨,៧លានដុល្លារ។ លទ្ធផលក្នុងត្រីមាសទី៣ នេះ បង្ហាញពី ការថយចុះរហូតដល់ ៥០,០% និង ៦៧,៩% ធៀបនឹងត្រីមាសទី១ និងត្រីមាសទី២។ ការអនុម័តវិនិយោគផ្នែកឧស្សាហកម្ម កើនដល់ ៣០២,០លានដុល្លារ ឬកើន ៣,១% ធៀបនឹងត្រីមាសទី១ និង កើនរហូតដល់ ១៦៥,៦% (ដោយសារកំណើន ៣៧,៥% ខាងផ្នែកសម្លៀកបំពាក់) ធៀបនឹងត្រីមាសទី២ ប៉ុន្តែវាធ្លាក់ចុះ ២៦,០% ធៀបនឹងកាលពីមួយឆ្នាំមុន។ ការអនុម័តវិនិយោគផ្នែកកសិកម្ម ធ្លាក់ចុះ ៩៥,៨% ពីមួយឆ្នាំទៅមួយឆ្នាំ ឬធ្លាក់ចុះ ៨៩,០ ធៀបនឹងត្រីមាសទី១ និងចុះ ៩៦,១% ធៀបនឹងត្រីមាសទី២។

ចំនួនភ្ញៀវទេសចរអន្តរជាតិមកដល់កម្ពុជាសរុប កើនដល់ ១.៤៧៥.៨០០នាក់ ឬកើន ៧,៤% ពីមួយឆ្នាំទៅមួយឆ្នាំ និងកើន ១,០% ធៀបនឹងត្រីមាសទី២ ប៉ុន្តែធ្លាក់ចុះ ២១,៤% ធៀបនឹងត្រីមាសទី១។ ទេសចរមកពីចិន មានចំនួនភាគរយខ្ពស់ជាងគេរហូតដល់ ៣៨,៨% នៃទេសចរអន្តរជាតិមកដល់សរុប ហើយបន្ទាប់មក គឺ ទេសចរមកពី វៀតណាម (១៦,០%) ថៃ (៧,៧%) ជប៉ុន (៣,៣%) កូរ៉េខាងត្បូង (៣,២%) ម៉ាឡេស៊ី (៣,២%) សហរដ្ឋអាមេរិក (៣,១%) បារាំង (២,២%) និង អង់គ្លេស (២,០%)។ គួរកត់សំគាល់ថា ទេសចរមកពីចិន បានធ្លាក់ចុះជាទៀងទាត់ តាំងពីប្រមាណ ៦៨៣.៤០០នាក់ នៅត្រីមាសទី១ ដល់ ៦០៩.១០០នាក់ នៅត្រីមាសទី២ និង ៥៧២.៥០០នាក់ នៅត្រីមាសទី៣។

នៅត្រីមាសទី៣ នេះ ជញ្ជីងពាណិជ្ជកម្មនៅមានឱនភាពរហូតដល់ ៨២៧,៥លានដុល្លារ ដែលបង្ហាញនូវកំណើន ៤០៨,៣% ពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែការធ្លាក់ចុះអស់ ៥៧,៦% ធៀបនឹងកម្រិតខ្ពស់បំផុតដល់ ១.៩៩០,៦លានដុល្លារ នៅត្រីមាសទី២ នៅពេលដែលតម្លៃនាំចេញឡើងដល់ ៣.៣៧៩,០លានដុល្លារ ហើយតម្លៃនាំចូលឡើងដល់ ៥.៣២៨,៦លានដុល្លារ។ តម្លៃនាំចេញកើនឡើងយ៉ាងទៀងទាត់ តាំងពី ៣.១៣៥,៤លានដុល្លារ នៅត្រីមាសទី៤ ឆ្នាំ២០១៨ រហូតដល់ ៤.២៦៣,៩លានដុល្លារ នៅត្រីមាសទី៣ ឆ្នាំ២០១៩ (កំណើន ១១,៨% ពីមួយឆ្នាំទៅមួយឆ្នាំ)។ ការនាំចេញសម្លៀកបំពាក់ កើនដល់ ៣.១៤៣,៨លានដុល្លារ ឬកើន ៩,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ គិតតាមប្រទេសគោលដៅនាំចេញ ហើយធៀបនឹងត្រីមាសមុន ការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក កើន ២៥,៤% (ដល់ ១.០០៦,៥លានដុល្លារ), ទៅសហភាពអឺរ៉ុប កើន ២០,៥% (ដល់ ៩៦៥,៤លានដុល្លារ), ទៅជប៉ុន កើន ៦៥,៦% (ដល់ ២៩១,២លានដុល្លារ), ទៅអង់គ្លេស កើន ៣៨,០% (ដល់ ២៧២,៩លានដុល្លារ), ទៅអាស៊ាន កើន ១៦,៧% (ដល់ ៤៨,២លានដុល្លារ), និងទៅប្រទេសផ្សេងៗទៀត កើន ១០,៣% (ដល់ ៥៥៩,៧លានដុល្លារ)។ ការនាំចេញគ្រឿងអេឡិចត្រូនិក កើន ៧០,៦% ពីមួយឆ្នាំទៅមួយឆ្នាំ និង កើន ១៤,៩% ធៀបនឹងត្រីមាសទី២។ ការនាំចេញគ្រឿងបង្គុំយានយន្ត ក៏កើនបាន ៤៨,៤% ពីមួយឆ្នាំទៅមួយឆ្នាំ និងកើន ២៤,៧% ធៀបនឹងត្រីមាសមុន។ ការនាំចេញផលិតផលកសិកម្ម ធ្លាក់ចុះ ១,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែកើន ១៨,៧% ធៀបនឹងត្រីមាសមុន ដោយសារកំណើនការនាំចេញ កៅស៊ូ ឈើ និង អង្ករ។

ការនាំចូលសរុបកើនដល់ ៥.០៩១,៤លានដុល្លារ ឬកើន ២៨,០% ពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែធ្លាក់ចុះ ៤,៥% ធៀបនឹងត្រីមាសមុន (៥.៣២៨,៦លានដុល្លារ)។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនេះ ជំរុញឡើងដោយសារកំណើនការនាំចូល សាំង (កើន ៣៦,៣% ដល់ ១១៨,៦លានដុល្លារ), ម៉ាស៊ូត (២,៧% ដល់ ១៦៦,៤លានដុល្លារ), សម្ភារសំណង់ (៦៦,៧% ដល់ ២៧១,២លានដុល្លារ), និងទំនិញនាំចូលផ្សេងៗទៀត (២៧,២% ដល់ ៤.៥៣៥,២លានដុល្លារ)។ ការនាំចូលបានថយចុះធៀបនឹងត្រីមាសមុន ដោយសារការនាំចូល ម៉ាស៊ូតធ្លាក់ចុះ ៣៣,៥% និង ទំនិញផ្សេងៗទៀតធ្លាក់ចុះ ៤,១%។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៣ ឆ្នាំ២០១៩ ចំណូលសរុបរបស់រដ្ឋាភិបាល កើនដល់ ៦.៣៦៤,៥ប៊ីលានរៀល ឬកើន ៣៦,៣% ពីមួយឆ្នាំទៅមួយឆ្នាំ ក្រោយបានធ្លាក់ចុះ ៩,៥% នៅត្រីមាសទី៤ ឆ្នាំ២០១៨ ប៉ុន្តែកើនបាន ០,១% ធៀបនឹងត្រីមាសមុន។ ចំណូលចរន្ត កើន ៣៦,៤% ពីមួយឆ្នាំទៅមួយឆ្នាំ ហើយកើន ១៣,៨% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៨ និងកើន ២៤,៥% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ ប៉ុន្តែធ្លាក់ចុះ ០,២% ធៀបនឹងត្រីមាសទី២។ ចំណូលពន្ធ និងពន្ធក្នុងស្រុក មាននិន្នាការស្រដៀងគ្នា។ ចំណូលពន្ធឡើងខ្ពស់បំផុតដល់ ៥.៦៦៣,៥ប៊ីលានរៀល នៅត្រីមាសទី២

---

អត្ថបទនេះ រៀបរៀងដោយលោក រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និង ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

រួចហើយធ្លាក់ចុះដល់ ៥.៤១៥,១ប៊ីលានរៀល នៅត្រីមាសទី៣។ ពន្ធក្នុងស្រុក ក្រោយបានឡើងខ្ពស់បំផុតនៅត្រីមាសទី២ បានរួមចុះវិញអស់ ៦,៣% ដល់ ៤.៦៣៤,១ប៊ីលានរៀល។ ចំណូលមិនមែនពន្ធ កើនដល់ ៨៩៤,១ប៊ីលានរៀល ឬកើន ៤៥,៣% ពីមួយឆ្នាំទៅមួយឆ្នាំ, កើន ៦៤,៨% ធៀបនឹងត្រីមាសទី១, និងកើន ៣៥,៧% ធៀបនឹងត្រីមាសទី២, ប៉ុន្តែធ្លាក់ចុះ ៤,៥% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៨។ ចំណូលជាមូលធន កើន ២៣,៩% ពីមួយឆ្នាំទៅមួយឆ្នាំ និងកើន ៥៨,៣% ធៀបនឹងត្រីមាសមុន។

ចំណាយសរុបកើនពី ៤.១៥០,៤ប៊ីលានរៀល នៅត្រីមាសទី១ ដល់ ៤.៩៩៧,៦ប៊ីលានរៀល នៅត្រីមាសទី២ និងដល់ ៥.៣៨៦,៥ប៊ីលានរៀល នៅត្រីមាសទី៣ (ធ្លាក់ចុះ ៨,១% ពីមួយឆ្នាំទៅមួយឆ្នាំ)។ ចំណាយជាមូលធន ធ្លាក់ចុះ ២,៥% ធៀបនឹងត្រីមាសទី២ ដល់ ១.៣៥៨,៦ប៊ីលានរៀល និងធ្លាក់ចុះ ៣១,៣% ធៀបនឹងត្រីមាសទី៣ ឆ្នាំមុន។ ចំណាយចរន្ត កើន ២៨,៩% ធៀបនឹងត្រីមាសទី១, កើន ១១,៧% ធៀបនឹងត្រីមាសទី២ និងកើន ៣,៧% ពីមួយឆ្នាំទៅមួយឆ្នាំ។

## អតិផរណា និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី៣ ឆ្នាំ២០១៩ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុប (CPI) នៅភ្នំពេញ ធ្លាក់ចុះអស់ ០,១ឯកតាភាគរយ ក្រោយបាននៅថេរត្រឹម ១,៩% ក្នុង ២ត្រីមាសមុន។ ធៀបនឹងត្រីមាសមុន សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សម្រាប់ស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រា ធ្លាក់ចុះ ០,៥ឯកតាភាគរយ ហើយសម្រាប់ថ្លៃដឹកជញ្ជូនវាកើន ២,៣ឯកតាភាគរយ ពីលើការធ្លាក់ចុះរបស់វា។

ធៀបនឹងត្រីមាសមុន ប្រាក់រៀលចុះថ្លៃ ០,៩% ទល់នឹងប្រាក់ដុល្លារ ដល់ ៤.០៨៦,៨រៀល/ដុល្លារ, ចុះថ្លៃ ៣,៧% ទល់នឹងប្រាក់បាតថៃ ដល់ ១៣៣,៧រៀល/បាត និងចុះថ្លៃ ១,១% ទល់នឹងប្រាក់ដុងវៀតណាម ដល់ ១៧,៧រៀល/១០០ដុង។

មាសឡើងថ្លៃក្នុង ៥ត្រីមាសចុងក្រោយ តាំងពី ១៤៦,១ ដុល្លារ/ជី នៅត្រីមាសទី៣ ឆ្នាំ២០១៨ រហូតដល់ ១៧៥,៧ ដុល្លារ/ជី នៅត្រីមាសទី៣ ឆ្នាំ២០១៩។

នៅត្រីមាសទី៣ ឆ្នាំ២០១៩ ម៉ាស៊ូត ចុះថ្លៃដល់ ៣.៤៩៩,៧ រៀល/លីត្រ ធៀបនឹង ៣.៥៩៥,៤រៀល/លីត្រ នៅត្រីមាសមុន។ សាំង ចុះថ្លៃដល់ ៣.៦២៩,៣រៀល/លីត្រ ធៀបនឹង ៣.៧៧០,២ រៀល/លីត្រ នៅត្រីមាសទី២។

## ប្រាក់ចំណូលប្រចាំថ្ងៃមធ្យមពិតរបស់ពលករងាយរងគ្រោះ

ផ្នែកនេះ ពិពណ៌នាដោយសង្ខេបពីស្ថានភាពរបស់ពលករងាយរងគ្រោះ ដោយផ្អែកលើអង្កេតនៅខែវិច្ឆិកា ២០១៩។ ជារួម អ្នករត់តុភោជនីយដ្ឋាន មានប្រាក់ចំណូលប្រចាំថ្ងៃទាបជាងគេ បន្ទាប់មកគឺ អ្នកស៊ីឈ្នួលធ្វើស្រែ ដែលរកបានតិចជាង ១០.០០០ រៀល/ថ្ងៃ។ កម្មករសំណង់មានជំនាញ រកចំណូលប្រចាំថ្ងៃបានខ្ពស់ជាងគេ បន្ទាប់មកគឺ កម្មករសំណង់គ្មានជំនាញ អ្នកលីសែង អ្នកលក់បន្លែតូចតាច កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប អ្នករើសអេតចាយ និង អ្នករត់ស៊ីក្លូ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះពីរប្រភេទ ពោលគឺ អ្នកលក់បន្លែតូចតាច និង កម្មករសំណង់គ្មានជំនាញ បានធ្លាក់ចុះធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន រីឯពលករងាយរងគ្រោះប្រភេទឯទៀតបានកើនចំណូលប្រចាំថ្ងៃ។

ក្នុងចំណោមពលករងាយរងគ្រោះទាំងអស់ កម្មករសំណង់មានជំនាញរកចំណូលប្រចាំថ្ងៃបានខ្ពស់ជាងគេ ដល់ ២៧.២២៥ រៀល បន្ទាប់មកគឺ កម្មករសំណង់គ្មានជំនាញ (១៨.៨១៤រៀល) អ្នកលីសែង (១៨.៨០២រៀល) អ្នកលក់បន្លែតូចតាច (១៨.៦៥១ រៀល) កម្មកររោងចក្រកាត់ដេរ (១៦.៥៧៨រៀល) អ្នករត់ម៉ូតូឌុប (១៤.៩០៤រៀល) អ្នករើសអេតចាយ (១៣.០៩៩រៀល) អ្នករត់ស៊ីក្លូ (១២.០៤៦រៀល) អ្នកស៊ីឈ្នួលធ្វើស្រែ (៩.៣៧៦រៀល) និង អ្នករត់តុភោជនីយដ្ឋាន (៨.៧២៤រៀល)។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប្រាក់ចំណូលប្រចាំថ្ងៃបានកើនឡើងសម្រាប់ កម្មករសំណង់មានជំនាញ (២,៤%) អ្នកលីសែង (២១,៧%) កម្មកររោងចក្រកាត់ដេរ (៥,១%) អ្នករើសអេតចាយ (៤,២%) អ្នករត់ស៊ីក្លូ (១៤,៧%) និង អ្នកស៊ីឈ្នួលធ្វើស្រែ (៤,៤%) ប៉ុន្តែវាបានធ្លាក់ចុះសម្រាប់ អ្នកលក់បន្លែតូចតាច (១១,៣%) និង កម្មករសំណង់គ្មានជំនាញ(០,៥%)។

ក្នុងចំណោមពលករក្នុងអង្កេត ៣៦០នាក់ក្នុង ៩ប្រភេទការងារ (លើកលែងតែកម្មកររោងចក្រកាត់ដេរចេញ) មានភាគច្រើនណាស់ដែលធ្វើចំណាកស្រុកពីខេត្ត មកធ្វើការនៅក្រុងភ្នំពេញ ឬសៀមរាប។ អ្នកទាំងនេះមកពី ព្រៃវែង (៣១,៤%) ស្វាយរៀង (២៤,៤%) តាកែវ (១៣,១%) កំពង់ស្ពឺ (១១,៧%) កណ្ដាល (៨,៦%) កំពត (៣,៦%) កំពង់ចាម (២,៨%) កោះកុង (០,៦%) ភ្នំពេញ (០,៦%) ក្រចេះ (០,៣%) និង បន្ទាយមានជ័យ (០,៣%)។ ក្នុងចំណោមពលករ ៣៦០នាក់នេះ មាន ៧១,៩% មកពីគ្រួសារធំៗមានសមាជិកដល់ ៤-៧នាក់, ៨៨,៦% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ, និង ៦៧,២% ធ្វើចំណាកស្រុកតែម្នាក់ឯងមកធ្វើការនៅទីក្រុង។ តបនឹងសំណួរថា តើប្រាក់ចំណូលរបស់អ្នកអាចទ្រទ្រង់ជីវភាពគ្រួសារបានឬទេ? មាន ៥,៦% ប្រាប់ថាទ្រទ្រង់បាន, ៣,៣% ថាមិនបានទេ, និង ៩១,១% ថាបានមួយភាគ។ គិតជាមធ្យម ប្រាក់ចំណូលរបស់ពលករចំណាយជាសំខាន់លើ ស្បៀងអាហារ (៩៦,៦%) កន្លែងស្នាក់នៅ (០,៣%) ដឹកជញ្ជូន (០,៥) និង ចំណាយផ្សេងៗទៀត (២,៦%)។

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១៣-១៩

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 930.5 | 56.5 | 169.8 | 117.1 | 62.9 | 99.5 | 30.4 | 45.2 | 39.8 | 17.2 | 48.2 | 1.9 |
| ឧស្សាហកម្ម | 3256.9 | 1002.5 | 1014.7 | 1436.4 | 982.2 | 259.6 | 193.4 | 408.2 | 325.0 | 292.9 | 113.7 | 302.0 |
| *. សម្លៀកបំពាក់* | 324.1 | 393.5 | 225.2 | 380.7 | 211.1 | 53.2 | 31.4 | 49.9 | 52.8 | 73.9 | 34.4 | 47.3 |
| សេវាកម្ម | 140.7 | 622.6 | 2734.4 | 1664.3 | 3858.6 | 110.2 | 2156.2 | 605.5 | 1479.8 | 1625.6 | 2518.2 | 849.7 |
| *. សណ្ឋាគារ និងទេសចរណ៍* | 106.0 | 446.9 | 98.6 | 1366.9 | 2759.6 | 75.2 | 106.6 | 68.3 | 1333.9 | 1618.8 | 2518.2 | 808.7 |
| សរុប | 4328.5 | 1583.9 | 3918.9 | 3217.7 | 4903.7 | 469.3 | 2380.0 | 1058.9 | 1844.7 | 1935.6 | 2680.1 | 1153.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 310.5 | 407.2 | -55.5 | 74.2 | 4.9 | 38.5 | -57.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 90.1 | -63.4 | 147.4 | -17.9 | 52.4 | 257.2 | 44.0 | -64.8 | 1513.7 | 312.5 | 12.6 | 8.9 |

Note: Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 227.3 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១៣-១៩

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 463.1 | 560.3 | 694.7 | 830.0 | 1210.8 | 505.9 | 425.8 | 509.0 | 583.7 | 683.4 | 609.1 | 572.5 |
| វៀតណាម | 854.1 | 905.8 | 987.8 | 959.7 | 835.4 | 186.8 | 199.9 | 197.7 | 215.9 | 186.9 | 214.8 | 235.7 |
| កូរ៉េខាងត្បូង | 435.0 | 424.4 | 395.3 | 357.2 | 345.0 | 126.1 | 48.5 | 483.9 | 78.8 | 95.7 | 43.6 | 47.4 |
| ថៃ | 221.3 | 279.5 | 349.9 | 398.1 | 394.9 | 83.7 | 76.1 | 75.5 | 147.0 | 97.9 | 76.3 | 113.9 |
| សហរដ្ឋអាមេរិក | 185.0 | 191.4 | 217.5 | 238.7 | 256.5 | 79.1 | 54.6 | 47.7 | 69.5 | 79.0 | 53.2 | 45.5 |
| ជប៉ុន | 206.9 | 215.8 | 193.3 | 191.6 | 203.4 | 59.0 | 38.7 | 47.7 | 65.1 | 60.2 | 40.4 | 48.9 |
| បារាំង | 131.5 | 141.1 | 145.7 | 150.3 | 166.4 | 56.6 | 29.4 | 33.5 | 51.4 | 59.4 | 27.3 | 32.9 |
| ចក្រភពអង់គ្លេស | 123.9 | 133.3 | 154.3 | 159.5 | 171.2 | 51.2 | 33.7 | 33.0 | 44.5 | 59.4 | 29.7 | 28.5 |
| ម៉ាឡេស៊ី | 130.7 | 144.4 | 149.4 | 152.8 | 179.3 | 44.8 | 41.0 | 49.4 | 65.8 | 48.7 | 43.2 | 46.5 |
| តាមផ្លូវអាកាស | 2017.7 | 2273.5 | 2476.0 | 2778.0 | 3312.7 | 1157.6 | 846.5 | 954.8 | 1137.9 | 1299.1 | 1054.8 | 1039.9 |
| តាមផ្លូវគោក និងទឹក | 2192.5 | 2229.3 | 2299.2 | 2331.4 | 2289.4 | 553.6 | 443.9 | 419.6 | 687.1 | 578.7 | 405.8 | 436.0 |
| សរុប | 4210.2 | 4502.8 | 4775.2 | 4980.4 | 5602.2 | 1711.3 | 1290.4 | 1374.4 | 1825.0 | 1877.9 | 1460.6 | 1475.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 1.3 | -24.6 | 6.5 | 32.8 | 2.9 | -22.2 | 1.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 17.5 | 7.0 | 6.1 | 4.3 | 12.5 | 129.3 | -158.8 | 9.9 | 8.0 | 9.7 | 13.2 | 7.4 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១៣-១៩ *

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 6982.4 | 8106.0 | 9256.4 | 10043.3 | 10772.9 | 2834.6 | 3000.2 | 3813.7 | 3135.4 | 3222.7 | 3379.0 | 4263.9 |
| សម្លៀកបំពាក់ | 5386.1 | 5960.5 | 6827.0 | 7308.0 | 8020.3 | 2092.1 | 2240.6 | 2871.0 | 2302.3 | 2463.4 | 2526.3 | 3143.8 |
| - សហរដ្ឋអាមេរិក | 2075.2 | 1963.6 | 2009.4 | 1831.5 | 1923.8 | 538.4 | 573.9 | 743.5 | 627.4 | 739.8 | 802.9 | 1006.5 |
| - សហភាពអឺរ៉ុប | 1969.6 | 2403.7 | 2903.9 | 2928.7 | 2782.2 | 670.1 | 805.2 | 916.7 | 763.4 | 719.2 | 801.1 | 965.4 |
| - អាស៊ាន | 60.2 | 83.3 | 103.4 | 98.4 | 106.9 | 28.6 | 32.7 | 33.0 | 41.1 | 38.1 | 41.3 | 48.2 |
| - ជប៉ុន | 278.7 | 383.1 | 524.2 | 655.5 | 701.2 | 224.7 | 165.2 | 276.6 | 224.3 | 262.9 | 175.8 | 291.2 |
| - ចក្រភពអង់គ្លេស | - | - | - | 439.8 | 904.0 | 219.5 | 203.9 | 382.5 | 201.1 | 211.5 | 197.7 | 272.9 |
| - ប្រទេសផ្សេងៗ | 1002.9 | 1126.8 | 1286.3 | 1354.2 | 1602.2 | 410.9 | 459.7 | 518.8 | 445.0 | 491.7 | 507.5 | 559.7 |
| គ្រឿងអេឡិចត្រូនិក | - | - | - | - | 380.0 | 76.2 | 90.9 | 83.4 | 78.3 | 71.9 | 123.8 | 142.3 |
| គ្រឿងយានយន្ត | - | - | - | - | 11.6 | 11.9 | 13.1 | 15.3 | 54.1 | 20.4 | 18.2 | 22.7 |
| កសិកម្ម | 554.5 | 624.4 | 548.8 | 534.1 | 706.4 | 205.9 | 166.0 | 213.6 | 265.5 | 210.4 | 177.7 | 211.0 |
| - កៅស៊ូ | 175.2 | 153.9 | 165.4 | 165.3 | 273.5 | 52.4 | 36.5 | 59.7 | 69.1 | 43.8 | 42.2 | 60.0 |
| - ឈើ | 73.6 | 132.0 | 46.3 | 47.2 | 100.5 | 30.0 | 34.0 | 42.0 | 36.3 | 22.2 | 35.2 | 42.4 |
| - ត្រី | 1.2 | 0.8 | 0.5 | 0.6 | 0.6 | 1.0 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 |
| - អង្ករ | 262.3 | 248.5 | 315.3 | 300.8 | 255.1 | 106.7 | 71.8 | 88.7 | 146.4 | 122.4 | 72.2 | 84.5 |
| - ផលិតផលកសិកម្មផ្សេងៗ | 42.4 | 89.1 | 21.3 | 20.2 | 76.7 | 15.8 | 23.6 | 23.2 | 13.6 | 21.9 | 28.1 | 24.1 |
| ផ្សេងៗ | 1088.2 | 1520.1 | 1880.2 | 2201.2 | 1654.7 | 448.6 | 489.6 | 630.4 | 435.2 | 456.6 | 532.9 | 744.0 |
| ការនាំចូលសរុប | 8639.4 | 10295.4 | 11494.5 | 15013.4 | 16815.4 | 4244.5 | 4496.0 | 3976.5 | 4187.6 | 4437.7 | 5328.6 | 5091.4 |
| សាំង | 306.4 | 334.7 | 377.3 | 384.8 | 256.7 | 64.9 | 60.8 | 87.0 | 107.8 | 121.1 | 117.1 | 118.6 |
| ម៉ាស៊ូត | 569.1 | 602.3 | 607.8 | 709.1 | 472.9 | 102.0 | 116.9 | 162.0 | 213.2 | 228.2 | 250.2 | 166.4 |
| សម្ភារសំណង់ | 80.8 | 117.6 | 164.4 | 253.2 | 304.3 | 100.7 | 138.7 | 162.7 | 162.5 | 170.8 | 231.4 | 271.2 |
| ផ្សេងៗ | 7682.6 | 9240.7 | 10345.1 | 13666.3 | 15781.6 | 3976.9 | 4179.7 | 3564.8 | 3704.2 | 3917.7 | 4729.9 | 4535.2 |
| ជញ្ជីងពាណិជ្ជកម្ម | -1610.9 | -2184.3 | -2238.1 | -4970.0 | -5974.1 | -1409.9 | -1495.9 | -162.8 | -1052.3 | -1215.0 | -1990.6 | -827.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | | 4.6 | 7.1 | 28.1 | -19.8 | 7.0 | 2.6 | 24.4 |
| ការនាំចេញសរុប | - | - | - | - | | 0.3 | 5.8 | 27.1 | -17.8 | 2.8 | 7.8 | 26.2 |
| ការនាំចូលសរុប | - | - | - | - | | 24.0 | 5.9 | -11.6 | 5.3 | 6.0 | 27.2 | -4.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 7.4 | 10.7 | 14.5 | 7.0 | 9.7 | 12.7 | 19.6 | 25.4 | 15.1 | 17.7 | 12.8 | 9.5 |
| ការនាំចេញសរុប | 14.3 | 16.1 | 14.2 | 8.5 | 7.9 | 23.7 | 14.2 | 23.1 | 11.0 | 13.7 | 12.6 | 11.8 |
| ការនាំចូលសរុប | 15.4 | 19.7 | 11.7 | 30.6 | 12.0 | 33.8 | -24.0 | -7.6 | 22.3 | 4.6 | 18.5 | 28.0 |

Note: Import data include tax-exempt imports.
Sources: Department of Trade Preference Systems, Ministry of Commerce; Customs and Excise Department, Ministry of Economy and Finance website

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១៣-១៩ (ប៊ីលានរៀល)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 8255.2 | 10543.4 | 11879.9 | 14201.5 | 16582.0 | 4357.6 | 5080.6 | 4670.3 | 5634.6 | 5097.5 | 6357.1 | 6364.5 |
| ចំណូលចរន្ត | 8233.2 | 10359.4 | 11759.0 | 14088.7 | 16481.4 | 4344.8 | 5035.2 | 4625.6 | 5543.5 | 5066.8 | 6322.2 | 6309.2 |
| ចំណូលពន្ធ | 7198.1 | 8995.2 | 10502.4 | 12196.5 | 14314.3 | 3984.9 | 4425.4 | 4010.2 | 4598.7 | 4524.3 | 5663.5 | 5415.1 |
| ពន្ធក្នុងស្រុក | 5728.1 | 7226.5 | 8591.7 | 10185.8 | 12338.7 | 3469.8 | 3850.4 | 3424.9 | 3903.2 | 3904.9 | 4944.9 | 4634.1 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1470.0 | 1822.7 | 1910.7 | 2010.7 | 1875.6 | 515.2 | 575.0 | 585.2 | 695.4 | 619.4 | 718.6 | 781.0 |
| ចំណូលមិនមែនពន្ធ | 1035.2 | 1310.3 | 1256.6 | 1892.2 | 2167.2 | 359.8 | 609.8 | 615.4 | 935.8 | 542.5 | 658.7 | 894.1 |
| ចំណូលលើទ្រព្យសម្បត្តិ | 84.0 | 88.5 | 77.3 | 116.0 | 127.2 | 7.7 | 130.5 | 12.6 | 46.4 | 177.4 | 34.0 | 30.2 |
| លក់ទំនិញ និងសេវា | 750.3 | 871.2 | 1047.1 | 1248.3 | 1517.0 | 341.0 | 388.9 | 527.8 | 817.9 | 330.7 | 531.2 | 798.5 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 200.8 | 350.5 | 132.2 | 528.0 | 523.1 | 11.1 | 87.4 | 75.0 | 80.5 | 34.5 | 93.5 | 65.5 |
| ចំណូលជាមូលធន | 73.4 | 184.0 | 121.0 | 113.4 | 100.5 | 12.9 | 45.4 | 44.7 | 91.1 | 30.7 | 35.0 | 55.4 |
| ចំណាយសរុប | 12535.7 | 13306.5 | 13849.5 | 13775.4 | 17251.0 | 3583.2 | 4706.2 | 5861.4 | 4876.3 | 4150.4 | 4997.6 | 5386.5 |
| ចំណាយជាមូលធន | 5567.5 | 5590.7 | 5290.3 | 3785.3 | 5207.2 | 812.9 | 1517.8 | 1978.3 | 1421.2 | 1025.0 | 1392.7 | 1358.6 |
| ចំណាយចរន្ត | 6968.3 | 7715.8 | 8544.6 | 9990.1 | 12043.7 | 2770.3 | 3188.5 | 3883.1 | 3455.1 | 3125.4 | 3604.9 | 4027.9 |
| បៀវត្សរ៍ | 2997.3 | 3755.5 | 4271.9 | 5381.7 | 6647.4 | 1760.3 | 1911.1 | 2148.8 | 1738.3 | 1820.2 | 1911.1 | 2102.0 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1563.0 | 1627.0 | 1742.9 | 1774.9 | 2314.8 | 469.9 | 621.1 | 597.2 | 817.2 | 729.2 | 1061.9 | 855.5 |
| ចំណាយចរន្តផ្សេងទៀត | 2408.0 | 2333.4 | 2529.8 | 2833.5 | 5394.3 | 1010.0 | 1277.4 | 1734.4 | 1716.9 | 1305.2 | 1693.8 | 1925.8 |
| សមតុល្យជាទូទៅ | -4280.6 | -2763.1 | -1969.6 | 426.1 | -669.1 | 774.5 | 374.4 | -1191.1 | 758.3 | 947.1 | 1359.6 | 978.0 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 4326.2 | 3972.1 | 3729.4 | 1878.9 | 3358.1 | 401.6 | 1064.4 | 413.1 | 634.4 | 652.8 | 895.5 | 608.8 |
| ហិរញ្ញប្បទានក្នុងស្រុក | 824.4 | -1428.7 | -2034.9 | -1858.7 | -2454.1 | 101.7 | 90.5 | -36.3 | 66.7 | -44.4 | -7.6 | 11.9 |

Source: Ministry of Economy and Finance website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១៣-១៩

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 3.0 | 3.9 | 1.2 | 3.1 | 2.9 | 2.3 | 2.7 | 2.5 | 2.4 | 1.9 | 1.9 | 1.8 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 3.9 | 4.9 | 4.0 | 5.6 | 3.4 | 1.9 | 2.9 | 2.5 | 2.5 | 2.1 | 2.1 | 1.6 |
| - ដឹកជញ្ជូន | -0.6 | -1.0 | -9.2 | -6.9 | 4.1 | 3.1 | 3.9 | 3.3 | 1.4 | -3.8 | -3.8 | -1.5 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4037.3 | 4036.2 | 4060.4 | 4053.7 | 4047.5 | 4012.4 | 4047.0 | 4073.7 | 4046.7 | 4006.6 | 4052.1 | 4086.8 |
| រៀលក្នុង ១ បាតថៃ | 133.1 | 124.9 | 119.4 | 115.5 | 120.0 | 127.7 | 127.4 | 124.2 | 124.2 | 127.4 | 128.9 | 133.7 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.3 | 19.1 | 18.7 | 18.2 | 17.9 | 17.8 | 17.9 | 17.7 | 17.5 | 17.4 | 17.5 | 17.7 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 175.9 | 152.3 | 140.6 | 151.2 | 151.5 | 160.3 | 157.6 | 146.1 | 147.3 | 156.6 | 157.1 | 175.7 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 5019.0 | 4852.1 | 3771.3 | 3004.0 | 3385.8 | 3679 | 3915.7 | 3784.3 | 3856.3 | 3413.9 | 3595.4 | 3499.7 |
| ថ្លៃសាំង (រៀល/លីត្រ) | 5264.2 | 5083.3 | 3951.7 | 3336.8 | 3716.0 | 3914 | 4120.3 | 4003.0 | 3893.0 | 3405.7 | 3770.2 | 3629.3 |

Sources: NIS, NBC; CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១៣-១៩ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 21260.1 | 26699.7 | 26665.5 | 31814.5 | 42575.3 | 46707.0 | 49421.9 | 52669.4 | 55214.3 | 58148.8 | 62699.5 | 67081.5 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 11508.3 | 15859.8 | 22157.6 | 25802.3 | 28743.5 | 28457.0 | 29926.1 | 31941.8 | 33228.9 | 33997.2 | 33548.0 | 34814.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2794.9 | -4359.1 | -6428.8 | -8148.5 | -11066.5 | -12381.1 | -12887.7 | -12996.4 | -14803.7 | -17381.0 | -18747.4 | -20263.2 |
| ឥណទានដល់វិស័យឯកជន | 27608.8 | 36244.6 | 46071 | 56458.8 | 66922.6 | 68686.5 | 72464.2 | 77925.6 | 82419.3 | 86574.4 | 91568.6 | 98320.3 |
| រូបិយវត្ថុទូទៅ | 32768.4 | 42559.5 | 48823.1 | 57616.6 | 71318.9 | 75164.0 | 79348.0 | 84611.3 | 88443.2 | 92146.0 | 96247.6 | 101895.8 |
| រូបិយវត្ថុ | 4878.2 | 6308.4 | 6741.4 | 7273.0 | 9428.4 | 9578.5 | 9553.9 | 10146.0 | 10226.8 | 10782.0 | 11274.5 | 13465.9 |
| រូបិយវត្ថុផ្សេងៗ | 21260.1 | 26699.7 | 42081.7 | 50343.8 | 61890.4 | 65585.5 | 69794.1 | 74465.2 | 78216.4 | 81364.0 | 84973.0 | 88429.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ | 14.6 | 29.9 | 14.7 | 18.0 | 23.8 | 24.1 | 21.6 | 21.3 | 24.0 | 22.6 | 21.3 | 20.4 |
| រូបិយវត្ថុ | 20.6 | 29.3 | 6.9 | 7.9 | 29.6 | 27.3 | 16.7 | 13.7 | 8.5 | 12.6 | 18.0 | 32.7 |
| រូបិយវត្ថុផ្សេងៗ | 13.6 | 30.0 | 16.1 | 19.6 | 22.9 | 23.7 | 22.3 | 22.4 | 26.4 | 24.1 | 21.7 | 18.8 |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយ ធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2017 | 2018 | | | | 2019 | | | | 2019 | | |
| | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នករត់ស៊ីក្លូ | 10793 | 11042 | 11285 | 10267 | 10503 | 11764 | 10567 | 11114 | 12046 | -6.4 | 8.2 | 14.7 |
| អ្នកលីសែង | 14942 | 15123 | 14915 | 15889 | 15454 | 15882 | 17323 | 16560 | 18802 | 16.1 | 4.2 | 21.7 |
| អ្នកលក់បន្លែតូចតាច | 17015 | 18343 | 20999 | 20141 | 21018 | 18912 | 21472 | 19197 | 18651 | 2.3 | -4.7 | -11.3 |
| អ្នករើសអេតចាយ | 11591 | 10664 | 13931 | 13288 | 12570 | 12941 | 12685 | 13123 | 13099 | -8.9 | -1.2 | 4.2 |
| អ្នករត់តុភោជនីយដ្ឋាន* | 22901 | 8226 | 8077 | 7945 | 8346 | 8299 | 8348 | 8564 | 8724 | 3.4 | 7.8 | 4.5 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 17341 | 8774 | 8486 | 8427 | 8984 | 8209 | 7909 | 9180 | 9376 | -6.8 | 8.9 | 4.4 |
| កម្មកររោងចក្រកាត់ដេរ | 14231 | 15268 | 14605 | 15316 | 15631 | 16073 | 15166 | 16076 | 16578 | 3.8 | 5.0 | 5.1 |
| អ្នករត់ម៉ូតូឌុប | 8093 | 14901 | 14429 | 15293 | 14637 | 14705 | 15104 | 14219 | 14904 | 4.7 | -7.0 | 1.8 |
| កម្មករសំណង់គ្មានជំនាញ | 8055 | 18082 | 15771 | 17539 | 18900 | 19820 | 17987 | 18322 | 18814 | 14.0 | 4.5 | -0.5 |
| កម្មករសំណង់មានជំនាញ | 14093 | 25578 | 25025 | 23276 | 26595 | 26265 | 24743 | 25235 | 27225 | -1.1 | 8.4 | 2.4 |

Notes: * Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. November 2015 data are not available. **Not available. Source: CDRI

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ**...

**សិក្ខាសាលាស្តីពី "ការចូលរួមក្នុងការស្រាវជ្រាវពីឧត្តមសិក្សា"** គឺ វិទ្យាស្ថាន CDRI បានរៀបចំឡើងដើម្បីផ្សព្វផ្សាយលទ្ធផលរកឃើញក្នុង កម្មវិធីស្រាវជ្រាវរយៈពេលបីឆ្នាំស្តីពី "ការស្រាវជ្រាវពីគោលនយោបាយ និងឥទ្ធិពលលើឧត្តមសិក្សានៅកម្ពុជា" ដែលផ្តល់មូលនិធិដោយ ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី។ សិក្ខាសាលានេះបានអញ្ជើញមកជួបជុំគ្នានូវ អ្នកចូលរួមមកពីខាង រដ្ឋាភិបាល វិស័យឯកជន សហគមន៍ស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍អន្តរជាតិ ជាដើម ដើម្បីពិភាក្សាពីទិសដៅទៅអនាគតសម្រាប់ការស្រាវជ្រាវពីឧត្តមសិក្សានៅកម្ពុជា។

**ពិធីបង្ហាញសៀវភៅ និងសន្និសីទស្តីពីគំនិតផ្តួចផ្តើមខ្សែក្រវាត់មួយផ្លូវមួយ**។ ព្រឹត្តិការណ៍នេះ វិទ្យាស្ថាន CDRI បានរៀបចំរួមគ្នាជាមួយ វិទ្យាស្ថានចិននៃការសិក្សាអន្តរជាតិ (CIIS) ក្រោមអធិបតីភាពនៃនាយកប្រតិបត្តិ CDRI ។

**សន្និសីទ និងពិពណ៌ឌីជីថលកម្ពុជាឆ្នាំ២០១៩**។ ព្រឹត្តិការណ៍នេះបាននាំមកជួបជុំគ្នានូវ វាគ្មិននិងអ្នកចូលរួម ជាង ១០០នាក់មកពីខាង រដ្ឋាភិបាល ឧស្សាហកម្មផ្នែកបច្ចេកវិទ្យាព័ត៌មាន ស្ថាប័នផ្នែកសិក្សាអប់រំនិងស្រាវជ្រាវ និង វិស័យឯកជន នៅកម្ពុជា នៅក្នុងតំបន់ និងក្នុងពិភពលោក។ នាយកប្រតិបត្តិ CDRI បានជួយសម្របសម្រួលវគ្គស្តីពី កម្លាំងមនុស្សឌីជីថលសម្រាប់សម័យឌីជីថល។ ការតាំងពិព័រណ៍រយៈពេលបីថ្ងៃ បានទាក់ទាញទស្សនិកជនដល់ជាងពីរម៉ឺននាក់។

**សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៩៖ ការប្រែក្លាយផ្នែកឌីជីថលឆ្លងទៅកាន់ឧស្សាហកម្ម ៤.០**។ ជាថ្មីម្តងទៀត សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទ ដោយនៅចុងបញ្ចប់បានប្រកាសថា វិទ្យាស្ថាន CDRI ជាធនាគារខួរក្បាល និងបានបញ្ជាក់ថា CDRI ត្រូវរក្សាទីតាំងបច្ចុប្បន្ននៅខ័ណ្ឌទួលគោក។ ចំណុចសំខាន់មួយនៃសន្និសីទនេះ គឺការចូលរួមនៃរ៉ូបុតមានរូបរាងជាមនុស្សផ្នែកសង្គមកិច្ចម្នាក់។

**ក្នុងពេលប្រជុំពេញអង្គប្រចាំឆ្នាំនៃក្រុមប្រឹក្សាភិបាល CDRI** លោកស្រី អេវ៉ា មីស្លីវិក ស្ថានិកជាទីគោរពរបស់ CDRI និង បណ្ឌិត Suthad Setboonsarng បានចប់បេសកកម្មពីក្រុមប្រឹក្សាភិបាលនៅខែមីនា។ ក្រុមប្រឹក្សាភិបាល បានអរគុណដល់អ្នកទាំងពីរចំពោះការងារដ៏មានតម្លៃ ខ្លាំងក្លា និងមោះមុត ជួយដល់ CDRI។

**ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់ រវាងវិទ្យាស្ថាន CDRI នឹងបណ្ឌិតសភាចិនផ្នែកវិទ្យាសាស្ត្រ (CAS)**។ ដោយផ្អែកលើគោលការណ៍មានផលប្រយោជន៍ទៅវិញទៅមក CDRI និង CAS បានព្រមព្រៀងរួមសហការគ្នាជាដៃគូ និងធ្វើការផ្លាស់ប្តូរគ្នាយ៉ាងទូលំទូលាយនូវ ឧបករណ៍បច្ចេកទេស និងបច្ចេកទេសវិភាគ ដើម្បីធ្វើការស្រាវជ្រាវដោយរួមសហការគ្នាក្នុងផ្នែក ការគ្រប់គ្រងធនធានទឹក វិទ្យាសាស្ត្រផ្នែកទឹក បច្ចេកវិទ្យាស្រោចស្រពបែបថ្មី កសិកម្ម អនាម័យ ការអប់រំ ថាមពលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចតាមមូលដ្ឋាន អភិបាលកិច្ច ការសម្រាលនិងការបន្សាំ នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងមូលដ្ឋាន។ សកម្មភាពនានានឹងផ្តោតជាដំបូងលើការស្វែងរក និងពង្រឹងប្រភពផ្នែកក្នុងនិងខាងក្រៅនៃមូលនិធិសម្រាប់ការស្រាវជ្រាវ។

## ការស្រាវជ្រាវ

### ផ្នែកកសិកម្ម

គម្រោងចំនួន ៥ កំពុងអនុវត្តទៅមុខ។ *ការវាយតម្លៃលទ្ធផលពាក់កណ្តាលអាណត្តិ លើគម្រោងរបស់ USAID/កម្ពុជា ស្តីពីសកម្មភាពជួយដោះស្រាយភាពងាយរងគ្រោះនៅតាមជនបទ និងស្ថិរភាពប្រព័ន្ធអេកូឡូស៊ី (HARVEST II)* ដែលផ្តល់មូលនិធិដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដោយរួមសហការជាដៃគូជាមួយក្រុមហ៊ុន Mitchell Group Inc (TMG) បានអនុវត្តចប់សព្វគ្រប់ និងបានផ្ញើទិន្នន័យអនុម័តរួច និងរបាយការណ៍ចុះសិក្សាដល់កន្លែងទៅឲ្យ TMG រួចហើយ។ គម្រោងផ្តល់មូលនិធិដោយ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ស្តីពី *ការវិភាគខ្សែសង្វាក់តម្លៃផ្លែស្វាយ* កំពុងជឿនលឿនទៅមុខយ៉ាងល្អ ដោយមានការសម្រេចជ្រើសយកឧបករណ៍ និងទីកន្លែងធ្វើអង្កេតរួចហើយ។ ប៉ុន្តែការវិភាគទិន្នន័យ និងការសរសេររបាយការណ៍ សម្រាប់គម្រោងផ្តល់មូលនិធិដោយ Sida ស្តីពី *ការអនុវត្តស្តង់ដាសុវត្ថិភាពក្នុងសាកវប្បកម្មកម្ពុជា៖ ករណីដំណាំបន្លែ* ត្រូវផ្អាកមួយរយៈ ព្រោះសមាជិកក្រុមស្រាវជ្រាវកំពុងមមាញឹកជាមួយគម្រោងផ្សេងៗទៀត។ ការចុះសិក្សាដល់កន្លែងសម្រាប់ *ការស្រាវជ្រាវស្តីពី ផលត្រឡប់ផ្នែកសេដ្ឋកិច្ចនៃវិនិយោគលើយុវជន ក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ដើម្បីឲ្យយុវជនអាចចូលបម្រើការងារ និងដើម្បីឲ្យមានការអភិវឌ្ឍសហគ្រិនភាពនៅកម្ពុជា* ដែលផ្តល់មូលនិធិដោយ កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UNDP) បានចប់សព្វគ្រប់ ហើយសព្វថ្ងៃកំពុងរៀបចំរបាយការណ៍។ ប្រធានក្រុមអនុវត្តគម្រោង *ចំណាកស្រុក ការផ្ញើប្រាក់ទៅផ្ទះ និងការអប់រំកុមារ នៅតាមជនបទកម្ពុជា* ដែលផ្តល់មូលនិធិដោយ អង្គការភាពជាដៃគូសម្រាប់គោលនយោបាយសេដ្ឋកិច្ច (PEP) បានទៅធ្វើទស្សនកិច្ចសិក្សា ៣សប្តាហ៍នៅសាកលវិទ្យាល័យ Auvergne ប្រទេសបារាំង ដែលនៅទីនោះ គាត់បានរៀបចំស្រេចបាច់ជាមួយទីប្រឹក្សានៃគម្រោង នូវវិធីសាស្ត្រសិក្សា។

នៅត្រីមាសទី២ ផ្នែកនេះបានរៀបចំសិក្ខាសាលាស្រាវជ្រាវមួយចំនួននៅ CDRI លើប្រធានបទ ដូចជា *ទំនាស់នៅប្រាសាទ*

*ព្រះវិហារ៖ កេរ្ដិ៍ដំណែលប្រវត្តិសាស្ត្រ ព្រំដែន និងការតស៊ូកសាងសន្តិភាព, ការចេញពីភាពក្រីក្រទៅកាន់វិបុលភាព, ផលប៉ះពាល់នៃការដាក់កម្រិតអតិបរមាលើការប្រាក់, បញ្ហាផ្សេងៗនៅ CDRI លើការប្រើសូហ្វវែរភាពក្រីក្រ* ជាដើម។ ផ្នែកនេះក៏បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលមួយ (សន្និសីទប្រចាំឆ្នាំ២០១៩ នៃអង្គការភាពជាដៃគូសម្រាប់គោលនយោបាយសេដ្ឋកិច្ច (PEP) នៅក្រុង Cap ប្រទេសអាហ្វ្រិកខាងត្បូង) ដែលរៀបចំឡើងដោយអង្គការ PEP ។

នៅត្រីមាសទី៣ ផ្នែកនេះបានរៀបចំសិក្ខាសាលាស្រាវជ្រាវមួយចំនួនទៀតដូចជា ស្ដីពី *ក្រមសីលធម៌ក្នុងការស្រាវជ្រាវ, អនាគតសេដ្ឋកិច្ចសម្រាប់អាស៊ីអាគ្នេយ៍ ចិន និងឥណ្ឌា, ការលើកកម្ពស់ជីវភាពធន់នឹងការប្រែប្រួលអាកាសធាតុ នៅតាមសហគមន៍ពឹងផ្អែកលើដំណាំស្រូវនៅតំបន់ទន្លេសាប* (ទទួលដំណើរការដោយ អង្គការស្បៀងអាហារនិងកសិកម្ម (FAO)), និង *សហគ្រិនភាព និងការអភិវឌ្ឍប្រកបដោយចីរភាព*។ ផ្នែកនេះក៏បានចូលរួមក្នុង សិក្ខាសាលាចាប់ដំណើរការបណ្ដាញសម្រាប់ក្រុមផ្ដល់គំនិតផ្នែកកសិកម្មនិងអភិវឌ្ឍន៍ជនបទ នៅមហាអនុតំបន់មេគង្គ (NARDT) ដែលរៀបចំដោយ វិទ្យាស្ថាននៃគោលនយោបាយនិងយុទ្ធសាស្ត្រ សម្រាប់កសិកម្មនិងអភិវឌ្ឍន៍ជនបទ (IPSARD) នៅក្រុងហាណូយ ប្រទេសវៀតណាម។

សកម្មភាពនៅត្រីមាសទី៤ មានតិចជាងនៅត្រីមាសទី៣។ ផ្នែកកសិកម្មបានចូលរួមក្នុងសិក្ខាសាលាស្រាវជ្រាវពីរ ស្ដីពី *ថាមពល និងទឹកក្នុងទន្លេមេគង្គ*, ហើយនិង *វេទិកាកសិករជាតិរៀបចំឡើងដោយ* វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា (NGO Forum)។

## ផ្នែកសេដ្ឋកិច្ច

គម្រោងរយៈពេល ៣ឆ្នាំ ស្ដីពី *ការប្រមើលឃើញពីការងារសម្រាប់យុវជន ពលករមានជំនាញទាប និងពលករជាស្ត្រីនៅមហាអនុតំបន់មេគង្គ ដែលអនុវត្តឡើងក្នុងក្របខ័ណ្ឌនៃ បណ្ដាញស្រាវជ្រាវនៅមហាអនុតំបន់មេគង្គ (GMS-Net)* បានចប់រួចរាល់ដោយមានការបោះពុម្ពផ្សាយកម្រងសៀវភៅមួយ និងសង្ខេបគោលនយោបាយមួយ។ ឯកសារចេញផ្សាយនានា បានផ្សព្វផ្សាយទៅដល់ បណ្ដាវិទ្យាស្ថានដៃគូ និងសាកលវិទ្យាល័យ និងទៅដល់អ្នកចូលរួមក្នុងសិក្ខាសាលា និងសន្និសីទនានា មានជាអាទិ៍ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៩ នៅខែមីនា។ ឯកសារទាំងនេះក៏មានចុះក្នុង វេបសាយរបស់ CDRI ដែរ។ គម្រោងនេះទទួលបានជំនួយគាំទ្រពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (IDRC) និងមានគោលដៅបង្ហាញភស្តុតាងបានមកពីការស្រាវជ្រាវ ដើម្បីផ្ដល់ព័ត៌មាន ដល់ការកំណត់ដំណោះស្រាយផ្នែកគោលនយោបាយសម្រាប់បញ្ហាផ្សេងៗដែល យុវជនមានជំនាញ/ការអប់រំទាប និងពលករជាស្រ្តី នៅមហាអនុតំបន់មេគង្គ ត្រូវប្រឈមមុខ។ ក្នុងចំណោមសំណើទាំង ២០ របស់ វិទ្យាស្ថានស្រាវជ្រាវ និងក្រុមផ្ដល់គំនិតនានានៅក្នុងអនុតំបន់នេះ បណ្ដាញនៅមហាអនុតំបន់មេគង្គ (GMS-Net) បានជ្រើសរើសនិងផ្ដល់មូលនិធិសម្រាប់សំណើស្រាវជ្រាវចំនួន ៨ ដែលមានសក្ដានុពលខ្លាំងជាងគេ។

ផ្នែកនេះដោយរួមសហការជាមួយ វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ODI) បានដំណើរការសិក្ខាសាលារយៈពេលកន្លះថ្ងៃ នៅថ្ងៃទី២៦ កុម្ភៈ ស្ដីពី *ការប្រមើលឃើញពីការប្រែក្លាយសេដ្ឋកិច្ចនៅកម្ពុជា៖ ការបូកសរុបសកម្មភាពថ្មីៗ* ដើម្បីពិនិត្យលើសំណួរស្រាវជ្រាវសំខាន់ៗ ៣ ពោលគឺ តើមានបញ្ហាប្រឈមអ្វីខ្លះសម្រាប់ការប្រែក្លាយផ្នែកសេដ្ឋកិច្ច និងការបង្កើតការងារ? តើមានវិស័យប្រកបដោយសក្ដានុពលអ្វីខ្លះ ដែលអ្នកកសាងគោលនយោបាយគួរផ្ដោតលើ? តើមានវិស័យ និង/ឬ ឧបសគ្គអ្វីខ្លះ ដែលកម្មវិធីគាំទ្រការប្រែក្លាយសេដ្ឋកិច្ច (SET) គួរធ្វើវិភាគបន្ថែមក្នុងឆ្នាំ២០១៩? អ្នកស្រាវជ្រាវក្នុងផ្នែកនេះ បានចូលរួមក្នុងសន្និសីទ និងសិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ជាច្រើន ដូចជា *គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព* នៅមជ្ឈមណ្ឌលថ្នាក់តំបន់នៃ UNDP នៅក្រុងបាងកក នៅថ្ងៃទី ១០ មករា, *គោលនយោបាយ និងទិសដៅនៃសេដ្ឋកិច្ចឌីជីថលរបស់កម្ពុជា* ដែលរៀបចំឡើងដោយ ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងធនាគារពិភពលោក នៅក្រុងភ្នំពេញ នៅថ្ងៃទី ១២-១៣ មីនា, *ជំនាញសម្រាប់ឧស្សាហកម្ម* ដែលរៀបចំឡើងនៅឯប្រទេសឡាវ ពីថ្ងៃទី ១១-១៥ មីនា ដោយ សាកលវិទ្យាល័យអប់រំគ្រូបង្រៀនក្រុង Zurich ។

នៅត្រីមាសទី២ ផ្នែកនេះបានចូលរួមក្នុងសកម្មភាពជាច្រើន រួមមាន សិក្ខាសាលាស្ដីពី *គំនិតផ្ដួចផ្ដើមខ្សែក្រវាត់មួយផ្លូវមួយនៅកម្ពុជា៖ ពិពិធកម្មសេដ្ឋកិច្ច និងការគ្រប់គ្រងបំណុល* ដែលរៀបចំឡើង ដោយអង្គការសហប្រជាជាតិនៅកម្ពុជា, *របាយការណ៍ហិរញ្ញវត្ថុ* រៀបចំឡើងដោយ ធនាគារជាតិនៃកម្ពុជា, *ការលើកកម្ពស់បរិស្ថាន មានបណ្ដាញបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ICT) ល្អសម្រាប់សហគ្រិនជាស្ត្រី* រៀបចំឡើងដោយ គណៈកម្មការសហប្រជាតិផ្នែកសេដ្ឋកិច្ចនិងសង្គម សម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក (UNESCAP), ហើយនិង*សិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពី ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ* (GIS Worklshop: Fundamentals of QGIS) រៀបចំដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) នៅឯការិយាល័យរបស់ខ្លួន, សិក្ខាសាលាស្ដីពី *ការបណ្ដុះបណ្ដាលអ្នកចុះអង្កេតសម្រាប់ដំណាក់កាលទី១នៃអង្កេតសម្រាប់គម្រោងស្រាវជ្រាវ លើអ្នកលក់ដូរតាមថ្នល់ការងាររបស់យុវជន និងការកាត់បន្ថយភាពក្រីក្រ (សមាសភាគទី២ នៃគម្រោងរបស់ Sida)*។

នៅត្រីមាសទី៣ ផ្នែកនេះបានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលជាច្រើនទាំងនៅក្នុង និងនៅក្រៅប្រទេស មានជាអាទិ៍ *ការតាក់តែងសទ្ទានុក្រមប្រជាសាស្ត្រ* រៀបចំដោយក្រសួងផែនការ, *និងការរៀនប្រមើលមើលនិងរៀបចំជាមុន* រៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ផ្នែកនេះបានចូលរួមក្នុងកិច្ចសន្ទនាផ្នែកគោលនយោបាយចំនួន ៣ សម្រាប់គម្រោងស្ដីពី *ពាណិជ្ជកម្មផ្នែកកសិកម្មរវាងប្រទេសចិន ជាមួយនឹង មីយ៉ាន់ម៉ា ឡាវ កម្ពុជា៖ ការវិភាគខ្សែសង្វាក់តម្លៃ* នៅក្រុងភ្នំពេញ វៀងចន្ទន៍ និង ប៉េកាំង រៀបចំ

ឡើងដោយ វិទ្យាស្ថាន CDRI, វិទ្យាស្ថានស្រាវជ្រាវពីសេដ្ឋកិច្ចសម្រាប់ឧស្សាហកម្មនិងពាណិជ្ជកម្ម (ERIIT), បណ្ឌិតសភាចិននៃវិទ្យាសាស្ត្រសង្គម (CASS)។ ផ្នែកនេះបានរៀបចំការបណ្ដុះបណ្ដាល ៣ វគ្គ សម្រាប់ក្រុមខ្លួន គឺមាន *ការបណ្ដុះបណ្ដាលអ្នកចុះអង្កេតសម្រាប់ដំណាក់កាលទី១ នៃអង្កេតសម្រាប់គម្រោងស្រាវជ្រាវលើអ្នកលក់ដូរតាមថ្នល់ ការងាររបស់យុវជន និងការកាត់បន្ថយភាពក្រីក្រ (សមាសភាគទី២ នៃគម្រោងរបស់ Sida), វគ្គចែករំលែកចំណេះដឹងពីប្រអប់ឧបករណ៍ KoBo,* និង*ការបណ្ដុះបណ្ដាលអ្នកចុះអង្កេតសម្រាប់អង្កេត GIZ-SME,* និងបានផលិតអត្ថបទ*សង្ខេបគោលនយោបាយមួយស្ដីពី ជំនាញ និងការប្រែក្លាយក្នុងឧស្សាហកម្មនៅកម្ពុជា* ដែលបោះពុម្ពផ្សាយដោយសាកលវិទ្យាល័យអប់រំគ្រូបង្រៀនក្រុង Zurich ។

### ផ្នែកអប់រំ

សម្រាប់*ការសិក្សាផ្ដល់មូលនិធិដោយ Sida អំពីការហ្វឹកហាត់កូនជាង* ក្រុមស្រាវជ្រាវបានប្រមូលយកទិន្នន័យលើបន្ទុកចំណាយនិងអត្ថប្រយោជន៍នៃគម្រោងការហ្វឹកហាត់កូនជាង អំពី ១០៥ក្រុមហ៊ុន ចាប់ពីដើមខែមករា *ដល់ចុងខែមីនា ២០១៩។* ការប្រមូលទិន្នន័យសម្រាប់ *ការធ្វើផែនទីភាពចម្រុះបែបនៃគ្រឹះស្ថានឧត្ដមសិក្សានៅកម្ពុជា* ដែលទទួលបានជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុពី ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី (DFAT) គ្រោងចប់រួចរាល់ នៅខែមីនា។ លទ្ធផលរកឃើញក្នុងការសិក្សាទាំងពីរ នឹងយកទៅចងក្រងជាឯកសារពិភាក្សារបស់ វិទ្យាស្ថាន CDRI ដោយគ្រោងបោះពុម្ពផ្សាយក្នុងឆ្នាំនេះ។

ក្រុមការងារផ្នែកអប់រំ បានរៀបចំសិក្ខាសាលាមួយស្ដីពី *ការចូលរួមក្នុងការស្រាវជ្រាវនៅឧត្ដមសិក្សា* នៅថ្ងៃទី ២៨ កុម្ភៈ ដើម្បីបង្ហាញលទ្ធផលរកឃើញជាដំបូងៗ នៃការស្រាវជ្រាវរបស់ផ្នែកនេះអំពីឧត្ដមសិក្សា។ លទ្ធផលរកឃើញបានយកមកផ្ដុំតាម ៥ប្រធានបទសំខាន់ៗ៖ ការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM), អន្តរជាតូបនីយកម្ម, ការលើកកម្ពស់ការស្រាវជ្រាវ, ប្រព័ន្ធបែងចែកប្រភេទ, និង អភិបាលកិច្ចនិងការផ្ដល់ទុន។ សិក្ខាសាលានេះមានអ្នកចូលរួម ១១០នាក់ មានជាអាទិ៍ ថ្នាក់ដឹកនាំផ្នែកអប់រំ សាស្ត្រាចារ្យ អ្នករដ្ឋបាល និងនិស្សិត មកពី ៤០គ្រឹះស្ថានឧត្ដមសិក្សា។

ផ្នែកអប់រំ បានដឹកនាំគណៈប្រតិភូមួយទៅធ្វើទស្សនកិច្ចស្វែងយល់ចាប់ពីថ្ងៃទី ២-៩ កុម្ភៈ ២០១៩ នៅប្រទេសអូស្ត្រាលី ជាពិសេសនៅក្រុង Melbourne និង Canberra ដើម្បីរៀនសូត្រពីការអភិវឌ្ឍឧត្ដមសិក្សានៅអូស្ត្រាលី។ គណៈប្រតិភូ រួមមានអ្នកតំណាងមកពី ក្រសួងអប់រំ យុវជន និងកីឡា, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, សាកលវិទ្យាល័យបាត់ដំបង, សាកលវិទ្យាល័យ ជា ស៊ីម កំចាយមា, វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន, ក្រុមហ៊ុន G Gears, និង វិទ្យាស្ថាន CDRI ។

នៅត្រីមាសទី២ CDRI បានចុះអនុស្សរណៈយោគយល់ជាមួយក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ ផ្នែកនេះបានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលមួយចំនួន ដូចជា *ការរៀនសូត្រផ្អែកលើស្ថានភាព និងការអភិវឌ្ឍកម្មវិធីសិក្សាក្នុងការអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ* និង *ការណែនាំបង្ហាញពីការធ្វើផែនការសម្រាប់ការសិក្សាវាយតម្លៃ* ហើយនិងក្នុងសិក្ខាសាលាស្ដីពី *សហគ្រិនភាពក្នុងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ* រៀបចំដោយសាកលវិទ្យាល័យពហុបច្ចេកទេសក្រុង Shenzhen ។

នៅត្រីមាសទី២ CDRI បានរៀបចំសិក្ខាសាលាមួយពីថ្ងៃទី ៩-២៥ កក្កដា ស្ដីពី *វិធីសាស្ត្របែបបរិមាណវិស័យ* បង្រៀនដោយ បណ្ឌិត អ៊ុន យាង និងបានចូលរួមក្នុងវេទិកាមួយរៀបចំដោយ CDRI នៅថ្ងៃទី៤ តុលា នៅក្រុងភ្នំពេញ ស្ដីពី *ការធ្វើពាណិជ្ជកម្មលើការស្រាវជ្រាវ និងនវានុវត្តន៍*។

ក្នុងឆ្នាំ២០១៩ ផ្នែកអប់រំបានផលិតសៀវភៅរបាយការណ៍ និងឯកសារពិភាក្សាមួយចំនួន មានជាអាទិ៍ *សេដ្ឋកិច្ចនយោបាយនៃកំណែទម្រង់បឋមសិក្សានៅកម្ពុជា* បោះពុម្ពផ្សាយដោយ Oxford, *កត្តានៃការជ្រើសយកមុខជំនាញចម្បងផ្នែកស្ទែម (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា STEM)៖ ការពិនិត្យបែបបរិមាណវិស័យលើនិស្សិតឆ្នាំដំបូង* នៅតាមសាកលវិទ្យាល័យកម្ពុជា បោះពុម្ពផ្សាយដោយ Routledge, *ហិរញ្ញវត្ថុសម្រាប់ឧត្ដមសិក្សាសាធារណៈនៅកម្ពុជា* ហើយនិង *អភិបាលកិច្ចសម្រាប់ឧត្ដមសិក្សាសាធារណៈនៅកម្ពុជា* បោះពុម្ពផ្សាយដោយ CDRI ។

### ផ្នែកបរិស្ថាន

ក្រុមអនុវត្តគម្រោងស្ដីពី *ការពង្រឹងសមត្ថភាពស្ត្រីសម្រាប់ភាពធន់នឹងអាកាសធាតុនៅកម្ពុជា* បានធ្វើការតាមដានជំនួយខ្នាតតូចផ្ដល់ទៅឲ្យបណ្ដាញស្ត្រីថ្នាក់មូលដ្ឋាន ចំនួន ១០ សម្រាប់ការអនុវត្តគំនិតផ្ដួចផ្ដើមធ្វើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ នៅតាមសហគមន៍។ ផ្នែកបរិស្ថានក៏បានផលិតអត្ថបទមួយ មានចំណងជើងថា *"សមត្ថភាពបន្សាំរបស់ស្ត្រីដើម្បីពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់កសិអេកូឡូស៊ីទាំងបួន នៅកម្ពុជា"* សម្រាប់បោះពុម្ពផ្សាយក្នុង*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ប្រចាំត្រីមាស។

សម្រាប់គម្រោងផ្ដល់មូលនិធិដោយ Sida ស្ដីពី *ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ* ក្រុមការងារបានបញ្ចប់របាយការណ៍ស្រាវជ្រាវ និងចាប់ផ្ដើមធ្វើការរចនារៀបចំការស្រាវជ្រាវ សម្រាប់ប្រធានបទទី២ ស្ដីពី *ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅតាមសហគមន៍*។ សម្រាប់គម្រោង *ការឆ្លើយតបរបស់ប្រជាជនទៅនឹងការប្រែប្រួលបរិស្ថាននៅអាងទន្លេមេគង្គក្រោម* ក្រុមស្រាវជ្រាវបានចម្លងចេញជាឯកសារនូវ កំណត់ត្រាបានពីការពិភាក្សាតាមក្រុមស្នូល ចំនួន ៦ និងបានចាត់ចែងទិន្នន័យបែបបរិមាណវិស័យបានពី ៣០ សម្ភាសន៍ជាលក្ខណៈបុគ្គលជាមួយ ពលករចំណាកស្រុកមកពីភូមិលិចទឹកនៅតាមដងទន្លេក្នុងក្រុងភ្នំពេញ។ ការចុះសិក្សាដល់កន្លែងមួយទៀតសម្រាប់គម្រោងនេះ បានធ្វើឡើងនៅខេត្តសៀមរាប និងរួមមាន ការពិភាក្សាតាមក្រុមស្នូលចំនួន ៦ ជាមួយនឹងប្រជាជនក្នុងមូលដ្ឋាន និង ការធ្វើសម្ភាសន៍អ្នកផ្ដល់ព័ត៌មាន

គន្លឹះ ១២នាក់ រួមមាន អាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងមកពី ៣មន្ទីរជំនាញខេត្ត គឺមាន បរិស្ថាន, ធនធានទឹក និងឧតុនិយម, និង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ រហូតមកដល់បច្ចុប្បន្ន គម្រោងនេះ បានចុះកិច្ចសន្យាជាមួយកសិករក្នុងមូលដ្ឋានចំនួន ២២នាក់ ដើម្បីឲ្យគាត់កត់ត្រាប្រចាំសប្ដាហ៍ពីធាតុអាកាសក្នុង មូលដ្ឋាន និងសកម្មភាពកសិកម្មរបស់ខ្លួន។ ការចុះសិក្សាដល់ កន្លែងសម្រាប់គម្រោងពហុប្រទេស ស្ដីពី *ការធ្វើកសិកម្មតាម កិច្ចសន្យាក្នុងតំបន់មេគង្គឡានឆាង* បានអនុវត្តឡើងក្នុងគ្រប់ ប្រទេសអ្នកចូលរួម។ វិទ្យាស្ថាន CDRI ដោយរួមសហការជាមួយ នាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAI-MAFF) បានធ្វើសម្ភាសន៍ជាមួយ កសិករ ក្រុមហ៊ុន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និង មន្ត្រី រដ្ឋាភិបាលជាន់ខ្ពស់ នានា។ វិទ្យាស្ថាន CDRI ក៏បានរួមសហការ ជាមួយ នាយកដ្ឋានកសិ-ឧស្សាហកម្ម រៀបចំសិក្ខាសាលាពិគ្រោះ យោបល់មួយនៅក្រុងភ្នំពេញ នៅថ្ងៃទី ១០ មករា ដែរ។ សិក្ខាសាលា បានប្រព្រឹត្តទៅ ក្រោមអធិបតីភាពនៃប្រធាននាយកដ្ឋានក្រសួង កសិកម្ម និងបានអញ្ជើញមកជួបជុំគ្នានូវ អ្នកតំណាងមកពី ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និង វិស័យ ឯកជន។

គម្រោងស្រាវជ្រាវស្ដីពី *ផលប៉ះពាល់នៃកម្មវិធីពាក់ព័ន្ធនឹងការ ប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និង យេនឌ័រ* កំពុងជឿនលឿនទៅមុខយ៉ាងល្អ។ គម្រោងនេះ បានបញ្ចប់សកម្មភាពស្វែងយល់ដល់កន្លែង នៅខេត្ត កំពង់ចាម និង កំពង់ធំ និងបានរៀបចំការប្រជុំលើកទី១ នៃគណៈកម្មាធិការ ដឹកនាំការងារ នៅថ្ងៃទី ១៤ មករា ហើយការប្រជុំចាប់ផ្ដើមអនុវត្ត គម្រោងបានធ្វើឡើងនៅថ្ងៃទី១២ មីនា ២០១៩ នៅក្រុងភ្នំពេញ។

នៅត្រីមាសទី២ផ្នែកនេះបានចូលរួមក្នុងសិក្ខាសាលាពីរគឺមាន ការប្រជុំបច្ចេកទេសលើកទី២ នៃគម្រោងកិច្ចសន្ទនាលើកកម្ពស់ ការស្រាវជ្រាវ នៅបណ្ដាប្រទេសក្នុងតំបន់មេគង្គឡានឆាង នៅ ក្រុងហាណូយ ហើយនិង សិក្ខាសាលាចាប់ផ្ដើមគម្រោងស្ដីពី *ការទូតលើបញ្ហាទឹកនៅអាងទន្លេមេគង្គ ដើម្បីឈានទៅកាន់ វិបុលភាពក្នុងអាងទាំងអស់គ្នា* នៅខេត្តសៀមរាប។

នៅត្រីមាសទី៣ ផ្នែកនេះបានចូលរួមក្នុងការប្រជុំបូកសរុប លទ្ធផលគម្រោងស្ដីពី *ការពង្រឹងសមត្ថភាពស្ត្រីសម្រាប់ភាពធន់ នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា* នៅក្រុងភ្នំពេញ។

នៅត្រីមាសទី៤ ផ្នែកបរិស្ថានបានចូលរួមក្នុងសិក្ខាសាលា ដូចតទៅ៖ សិក្ខាសាលាថ្នាក់ឃុំស្ដីពី *លទ្ធផលស្រាវជ្រាវឃើញ* និង *ការរាយការណ៍ជូនសហគមន៍វិញ* នៅក្រុងកំពង់ចាម, សិក្ខាសាលា ថ្នាក់ជាតិ ស្ដីពី *ផលប៉ះពាល់នៃកម្មវិធីពាក់ព័ន្ធនឹងការប្រែប្រួល អាកាសធាតុនៅកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ* នៅក្រុងភ្នំពេញ, និងការប្រជុំក្រុមដឹកនាំការងារ នៅក្រុងភ្នំពេញ។

**ផ្នែកអភិបាលកិច្ច**

នៅត្រីមាសទី១ ក្រុមស្រាវជ្រាវ បានធ្វើការបកប្រែជាភាសាខ្មែរ នូវឯកសារពិភាក្សាស្ដីពី *យុវជន និងមនុស្សជំនាន់មុននៅ កម្ពុជា៖ ទំនាក់ទំនងរវាងទាំងពីរជំនាន់ និងទស្សនៈសង្គម និង នយោបាយ*។ ផ្នែកនេះ ក៏បានធ្វើការត្រៀមរៀបចំមួយចំនួន ដើម្បីដំណើរការសិក្ខាសាលាផ្សព្វផ្សាយមួយ នៅដើមខែមេសា សម្រាប់ចែករំលែកជាមួយមន្ត្រីថ្នាក់ក្រោមជាតិនូវ លទ្ធផលអង្កេត លើយុវជន។

អ្នកស្រាវជ្រាវម្នាក់ បានធ្វើជាអ្នកពិនិត្យឡើងវិញនូវ ឯកសារ ព្រាងមួយជំពូកស្ដីពី *ស្ត្រីនៅក្នុងមុខងារសាធារណៈ និងដឹកនាំ* សម្រាប់របាយការណ៍របស់ក្រសួងកិច្ចការនារីមួយ មានចំណងជើង ថា *ការវាយតម្លៃផ្នែកយេនឌ័រនៅកម្ពុជា*។ អ្នកស្រាវជ្រាវម្នាក់ទៀត បានលើកបង្ហាញនូវ ឯកសារមួយស្ដីពី *បញ្ហាប្រឈមនៃអ្នក បោះឆ្នោតកម្ពុជាដែលមានកំណើត* ក្នុងទសវត្សរ៍១៩៨០ និង ១៩៩០ នៅក្នុងសន្និបាតប្រចាំឆ្នាំរៀបចំឡើងដោយ សមាគមសិក្សា ពីអន្តរជាតិ (ISA) នៅក្រុង Toronto ពីថ្ងៃទី ២៧-៣០ មីនា ២០១៩ ។

នៅត្រីមាសទី២ ផ្នែកនេះបានចូលរួមក្នុងសិក្ខាសាលា និង ព្រឹត្តិការណ៍ជាច្រើន មានជាអាទិ៍ *សិក្ខាសាលាផ្សព្វផ្សាយនិង ចែករំលែកចំណេះដឹង* រៀបចំឡើងដោយ CDRI នៅ មជ្ឈមណ្ឌល សហប្រតិបត្តិការកម្ពុជា-កូរ៉េ នៅថ្ងៃទី៥ មេសា, *សិក្ខាសាលា ចែករំលែកចំណេះដឹង* រៀបចំឡើងដោយ សហភាពសហព័ន្ធ យុវជនកម្ពុជា នៅថ្ងៃទី២៦ មេសា, វគ្គបណ្ដុះបណ្ដាលស្ដីពី *កម្មវិធី កសាងសមត្ថភាព សម្រាប់នវានុវត្តន៍ក្នុងវិស័យសាធារណៈនៅ កម្ពុជា* រៀបចំឡើងដោយ អង្គការសម្រាប់សហប្រតិបត្តិការនិង អភិវឌ្ឍន៍សេដ្ឋកិច្ច(OECD) កូរ៉េ នៅឯវិទ្យាស្ថានជាតិសម្រាប់ការ អប់រំអន្តរជាតិ (NIIED), និង *សន្និសីទអាស៊ី ស្ដីពីវិទ្យាសាស្ត្រ សង្គម* (ACSS) លើកទី១០ រៀបចំឡើងដោយ ACSS នៅថ្ងៃទី ២០-២២ ឧសភា នៅក្រុងតូក្យូ ប្រទេសជប៉ុន។

នៅឆមាសទី២ ឆ្នាំ២០១៩ ផ្នែកនេះបានបោះពុម្ពផ្សាយ ឯកសារមួយស្ដីពី *ការវិភាគយេនឌ័រ*។ ក្រុមស្រាវជ្រាវក៏បានចូលរួម ក្នុងវគ្គបណ្ដុះបណ្ដាលមួយ រៀបចំឡើងដោយផ្នែកអប់រំ នៅ ខែកក្កដា ស្ដីពី *ការបណ្ដុះបណ្ដាលពីវិធីសាស្ត្របែបគុណវិស័យ*។ នៅថ្ងៃ២៥ កក្កដា ផ្នែកអភិបាលកិច្ចបានរៀបចំវគ្គបណ្ដុះបណ្ដាល មួយសម្រាប់បុគ្គលិកក្នុងផ្នែកខ្លួន ស្ដីពី *ការបណ្ដុះបណ្ដាល ពីការស្រាវជ្រាវ៖ សីលធម៌ក្នុងការស្រាវជ្រាវ*។ ក្នុងចន្លោះពី ខែសីហា ដល់ តុលា ផ្នែកនេះបានចំណាយពេលប្រមាណពីរ សប្ដាហ៍ធ្វើការបណ្ដុះបណ្ដាលពី *សុវត្ថិភាពក្នុងអ៊ិនធើណិត*។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

**សិក្ខាសាលាពិគ្រោះយោបល់ សម្រាប់ការសិក្សាច្រើនប្រទេស ស្ដីពី ការធ្វើកសិកម្មតាមកិច្ចសន្យានៅតំបន់មេគង្គ**។ សិក្ខាសាលានេះ វិទ្យាស្ថាន CDRI បានរៀបចំឡើងដោយរួមសហការជាមួយនាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAI-MAFF) ហើយ ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងកសិកម្ម បានអញ្ជើញចូលរួមជាអធិបតី។ ក្រុមតាមប្រទេសចំនួន ៥ បានធ្វើរបាយការណ៍ពីការជឿនលឿនការងារខ្លួន បានលើកបង្ហាញពីបញ្ហាទើបផុសឡើង និងបានពិភាក្សាពីបញ្ហាប្រឈម និងការប្រមើលឃើញពីការធ្វើកសិកម្មតាមកិច្ចសន្យានៅក្នុងតំបន់។

**ពិធីបើកដំណើរការជាផ្លូវការនៃ វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI)**។ នាយកប្រតិបត្តិ CDRI បានចូលរួមក្នុងពិធីនេះជាមួយអ្នកតំណាង ១៧០នាក់ទៀត មកពី ១៨ប្រទេស រួមមាន អ្នកការទូតបរទេស អ្នកកសាងគោលនយោបាយ តំណាងអង្គការអន្តរជាតិ អ្នកសិក្សាអប់រំ អ្នកស្រាវជ្រាវ និងនិស្សិត។ AVI ជាវិទ្យាស្ថានផ្ដល់យោបល់ឯករាជ្យមួយមានទីតាំងនៅក្រុងភ្នំពេញ និងមានមជ្ឈមណ្ឌលស្រាវជ្រាវស្វយ័តបួន គឺ មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាយុទ្ធសាស្ត្រ មជ្ឈមណ្ឌលសម្រាប់នវានុវត្តន៍ផ្នែកអភិបាលកិច្ច មជ្ឈមណ្ឌលសម្រាប់ការសិក្សាពីការអភិវឌ្ឍប្រកបដោយចីរភាព និង មជ្ឈមណ្ឌលសម្រាប់ការសិក្សាពីវប្បធម៌ និងសន្តិភាព។ ដោយមានពាក្យស្លោកថា "តភ្ជាប់ប្រជាជន តភ្ជាប់ចំណេះដឹង តភ្ជាប់សកម្មភាព" AVI មានចក្ខុវិស័យក្លាយជាស្ថាប័នផ្ដល់គំនិតឈានមុខនៅអាស៊ី ដោយរួមចំណែកកសាងសង្គមអាស៊ីនានាឲ្យមានសន្តិភាព ភាពសម្រាប់គ្រប់គ្នា ភាពបន្សាំ និងចីរភាព និងលើកស្ទួយគុណតម្លៃអាស៊ីនៃ មនុស្សជាតិ សន្តិភាព និងភាពចម្រុះផ្នែកវប្បធម៌។

**ការពិគ្រោះយោបល់លើកទី១ ជាមួយក្រុមផ្ដល់គំនិតនានា** ក្រោមជំនួយឧបត្ថម្ភពី លេខាធិការដ្ឋានអាស៊ាន និងអនុវត្តឡើងដោយ នាយកដ្ឋានសហគមន៍សេដ្ឋកិច្ច-វប្បធម៌អាស៊ាន គឺមានការចូលរួមពី អ្នកស្រាវជ្រាវមកពីក្រុមផ្ដល់គំនិត និងស្ថាប័នស្រាវជ្រាវនានាក្នុងតំបន់អាស៊ាន និងពី អ្នកតំណាងមកពីបណ្ដាញសាកលវិទ្យាល័យអាស៊ាន អង្គការយូនីសេហ្វ និងអង្គការស្ត្រីសហប្រជាជាតិ (UN Women)។ ការពិភាក្សាបានគូសរំលេចពីផលប៉ះពាល់នៃសេដ្ឋកិច្ចឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាទៅលើ រចនាសម្ព័ន្ធការងារនៅក្នុងតំបន់ ពីសារៈសំខាន់នៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដើម្បីដោះស្រាយកង្វះខាតផ្នែកទិន្នន័យ ជាពិសេសក្នុងពេលមានគ្រោះមហន្តរាយ និងពីតម្រូវការភ្ជិតគម្លាតរវាងប្រទេសក្រីក្រនឹងប្រទេសធូរធារ និងរវាងប្រជាជនមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងអ្នកដែលពុំមានលទ្ធភាពនេះ។

**ការពិភាក្សាតុមូល ស្ដីពី "លទ្ធភាពសម្រាប់ការប្រែក្លាយសេដ្ឋកិច្ចនៅកម្ពុជា៖ ការបូកសរុបសកម្មភាពថ្មីៗ"** គឺ វិទ្យាស្ថាន CDRI បានរៀបចំឡើងដោយរួមសហការជាដៃគូជាមួយ កម្មវិធីជួយគាំទ្រការប្រែក្លាយសេដ្ឋកិច្ច (SET) របស់វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ODI) ដែលផ្ដល់មូលនិធិដោយ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី។ អ្នកតំណាងមកពីខាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សហគមន៍ស្រាវជ្រាវនិងអភិវឌ្ឍន៍ថ្នាក់ជាតិ បានមកចូលរួមពិភាក្សាពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា ឧបសគ្គផ្សេងៗលើការប្រែក្លាយសេដ្ឋកិច្ចទៅមុខទៀត វិធានការសម្រាប់ជំនះឧបសគ្គ និងវិស័យមានសក្ដានុពលច្រើនដែលកម្មវិធី SET គួរផ្ដោតការយកចិត្តទុកដាក់ និងវិភាគថែមទៀត។

*តទៅទំព័រ ២០*

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា
*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*
ឆ្នាំទី២៣ ឆ្នាំ២០១៩

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវការវាយតម្លៃឯករាជ្យពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខាអាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក្ដី។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ពផ្សាយ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ពផ្សាយ ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ +៨៥៥២៣៨៨១៧០១/៨៨១៩១៦/៨៨៣៦០៣ 📠 +៨៥៥២៣៨៨០៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសម្រួល: អ៊ុំ ចាន់ថា
កែសម្រួលផលិតកម្ម: ម៉េន ច័ន្ទធីតា
សហគ្រាសបោះពុម្ព Go Invent Media (GIM), រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៩ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈវេបសាយ www.cdri.org.kh